សំរាប់លក់

ក្រសួងអប់រំ យុវជន និងកីឡា

# ផែនដីនិងបរិស្ថានវិទ្យា

១១

## កំណែ



គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

# ជំពូក១ ភពផែនដី

## មេរៀនទី១ ភពផែនដី

**សំណួរ១ តើផ្នែករឹងរបស់ផែនដីមានប៉ុន្មានស្រទាប់? អ្វីខ្លះ ?**

**ចម្លើយ:** ផ្នែករឹងរបស់ផែនដីមាន បីស្រទាប់គឺ

- ស្នូល
- ម៉ង់តូ
- សំបក ។

**សំណួរ២ ចូររៀបរាប់ពីដំណើរវិវត្តនៃបរិយាកាសរបស់ផែនដី ។**

**ចម្លើយ:** ការវិវត្តនៃបរិយាកាសរបស់ផែនដីមាន៖

បរិយាកាសផែនដីដំបូង មានតែ អេល្យូម និងអ៊ីដ្រូសែន ក្រោយមក ដោយមានបន្ទុះភ្នំភ្លើងក៏បានកកើតជាឧស្ម័នជាច្រើន ដូចជា ចំហាយទឹក ឧស្ម័នកាបូនិច អាម៉ូញាក់ និងមេតាន ។ ក្រោយមកពន្លឺព្រះអាទិត្យបានបំលែងឧស្ម័នទាំងនេះក្លាយជា អ៊ីដ្រូសែននិងអុកស៊ីសែនបន្តូច ។

នៅពេលមានជីវិតកើតឡើង (ស្យាណូបាក់តេរី និងរុក្ខជាតិបៃតងមួយចំនួន)មានការ ប្រើប្រាស់ឧស្ម័នកាបូនិចបណ្ដាលឱ្យបរិមាណអុកស៊ីសែន មានការកើនឡើងជាមួយនឹងការកើនឡើងនៃចំនួនភាវៈរស់ជាបន្តបន្ទាប់រហូតបានជាបរិយាកាសបច្ចុប្បន្ន ។

**សំណួរ៣ តើជនជនជាតិក្រិចសម័យដើមពន្យល់អំពីរាងស្វ៊ែរបស់ផែនដី តាមវិធីណាខ្លះ ?**

**ចម្លើយ:** ជនជាតិក្រិចសម័យដើម ពន្យល់ពីរាងស្វ៊ែរបស់ផែនដីបានតាមរយៈ ការសង្កេតដោយភ្នែកទទេគឺ លោកអារីស្តូត បានធ្វើការសង្កេតទៅលើស្រមោល រាងកោងនៅក្នុងព្រះចន្ទជា ស្រមោលរបស់ផែនដីពេលមានចន្ទគ្រាស និងការសង្កេតឃើញតារាជាច្រើនបានលេចឡើងនៅជើង មេឃភាគខាងត្បូង ។

**សំណួរ៤ តើលោក អឺរ៉ាតូស្ថែនវាស់ទំហំផែនដីដូចម្ដេច ?**

**ចម្លើយ:** លោក អឺរ៉ាស្តែន បានវាស់ទំហំរបស់ផែនដីតាម

រយៈ ការវាស់ស្រមោលរបស់វត្ថុនៅលើផែនដី ។

**សំណួរ៤ ហេតុអ្វីបានជាផែនដីប៉ោងនៅត្រង់អេក្វាទ័រនិងសំប៉ែតនៅប៉ូលទាំងពីរ ?**

**ចម្លើយ:** បានជាផែនដីប៉ោងនៅតំបន់អេក្វាទ័រពីព្រោះ តំបន់នេះមានខ្សែរវណ្ណវែងជាងគេ ដែលធ្វើឱ្យផែនដីវិលលឿនត្រង់តំបន់នេះជាហេតុធ្វើអោយកម្លាំងទំនាញ មានឥទ្ធិពលខ្សោយនៅតំបន់នេះទើបផែនដីមានរាងប៉ោងនៅតំបន់មានរាង ប៉ោង ។

## មេរៀនសង្ខេប

- ភពផែនដីកើតឡើងកាលពីប្រហែល 4600 លានឆ្នាំមុន ។ ផ្នែករឹងបានចុះត្រជាក់ក្លាយជាស្រទាប់រូបធាតុផ្សេងៗគ្នា។ ទ្វីបមហាសមុទ្រ បរិយាកាស និងភាវៈរស់ក៏វិវត្តបន្តរហូត ដល់បច្ចុប្បន្នឆ្លងកាត់រយៈពេលរាប់លានឆ្នាំ។
- នៅ300ឆ្នាំមុនគ.ស លោកអារីស្តូតបានលើកអំណះអំណាងមួយស្តីអំពីរាងស្វៃរបស់ផែនដី នៅពេលមានចន្ទគ្រាសនិងការសង្កេតតារាដែលលេចចេញពីក្រោមជើងមេឃ ភាគខាងត្បូង។
- ប្រហែល 200 ឆ្នាំមុនគ.ស លោកអ៊ីរ៉ាតូស្តែន ដែលជាគណិតវិទូ និងតារាវិទូជនជាតិក្រិចបានគណនាឃើញទំហំផែនដីតាមរយៈការវាស់ស្រមោលវត្ថុនៅលើផែនដី ។
- បច្ចុប្បន្នយើងឃើញថាផែនដីមានអង្កត់ផ្ចិតជាមធ្យមប្រវែង 12750 km ខ្សែវណ្ឌជាមធ្យមប្រវែង400041.47 km និងមានរាងអេលីបស្វូអ៊ីត ។

# មេរៀនទី២ កម្លាំងទំនាញផែនដី

**សំណួរ១ តើកត្តាអ្វីខ្លះដែលកំណត់កម្លាំងទំនាញរវាងវត្ថុទាំងពីរ ?**

**ចម្លើយ:** កត្តាដែលកំណត់កម្លាំងទំនាញរវាងវត្ថុទាំងពីរគឺ:

ម៉ាសរបស់វត្ថុនិងចំងាយរវាងវត្ថុពីរ ។

**សំណួរ២ តើកត្តាអ្វីខ្លះធ្វើឱ្យផែនដីធ្វើដំណើរ ក្នុងគន្លងជុំវិញព្រះអាទិត្យ ?**

**ចម្លើយ:** កត្តាដែលធ្វើឱ្យផែនដីវិលជុំវិញព្រះអាទិត្យគឺ

និចលភាព និងកម្លាំងទំនាញ ។

**សំណួរ៣ ចូរអធិប្បាយពីកំណកំណើតដែនម៉ាញេទិចរបស់ផែនដី ។**

**ចម្លើយ:** ដែនម៉ាញេទិចរបស់ផែនដីកើតឡើងពី ចរន្តលំហូរនៃស្នូលក្រៅដែលបណ្តាលមកពីរង្វិលខ្វាល់និងរង្វិលនៃរូបធាតុរបស់ស្នូលក្រៅ ។

**សំណួរ៤ តើសំរាងប៉ូលកើតឡើងដូចម្តេច ?**

**ចម្លើយ:** សំរាំងប៉ូលកើតឡើងពីភាគល្អិតនៃកាំរស្មីព្រះអាទិត្យបង្កើត បានជាចរន្តអគ្គិសនី ហើយវាធ្វើចលនាជុំវិញប៉ូលម៉ាញេទិច ជំរុញឱ្យអេឡិចត្រុងទៅក្នុងខ្សែដែន បន្ទាប់មកអេឡិចត្រុងរុំព័ទ្ធជាស្លៀជុំវិញដែន បានប៉ះជាមួយម៉ូលេគុលអាសូត និង អុកស៊ីសែនធ្វើឱ្យឧស្ម័នក្នុងបរិយាកាសបានបញ្ចេញអេឡិចត្រុង អណ្តែតទៅកាន់ ខ្សែដែនខាងលើ ហើយនៅពេលវាធ្លាក់ មកកាន់គន្លងខាងក្រោមវិញវាបានបញ្ចេញពន្លឺយ៉ាងស្រស់ស្អាតដែលអាចមើលឃើញហៅថា សំរាងប៉ូល ។

**សំណួរ៥ ប្រសិនបើរង្វិលខ្វាល់របស់ផែនដីយឺតជាងបច្ចុប្បន្នតើអ្នកគិតថាដែនម៉ាញ៉េទិចនឹងប្រែប្រួលដូចម្តេច ?**

**ចម្លើយ:** ប្រសិនបើរង្វិលខ្វាល់របស់ផែនដី យឺតជាងពេលបច្ចុប្បន្ន ខ្ញុំគិតថាដែនម៉ាទិចរបស់ផែនដីនឹងកាន់តែខ្សោយ ឬក៏អាចឈានទៅរកការបាត់បង់ដែនម៉ាញេទិចតែម្តង ដូចព្រះចន្ទនិង ភពសុក្រជាដើម ព្រោះភពទាំងនេះមាន ទំហំតូចពុំអាចមាន រង្វល់រូបធាតុ ខាងក្នុងស្នូលខ្លាំង និងមានរង្វិល

ខ្វាល់យឺត ។

## ៤ មេរៀនសង្ខេប

➤ កម្លាំងទំនាញនិងកម្លាំងម៉ាញេទិចជាកម្លាំងរបស់ផែនដី កម្លាំងទំនាញគឺជា កម្លាំងដែលទាញវត្ថុទាំងឡាយ ឱ្យឆ្ពោះទៅរកគ្នា ។ ម៉ាសរបស់វត្ថុនិងចម្ងាយរវាងវត្ថុជះឥទ្ធិពលដល់កម្លាំងទំនាញ ។ ផែនដីធ្វើចលនាជុំវិញព្រះអាទិត្យបានដោយសារនិចលភាព និងទំនាញ ។

➤ ដែនម៉ាញេទិចកើតឡើងពីរង្វិល់នៃស្នូលក្រៅនិងរង្វិលខ្វាល់របស់វា ។ ដែនម៉ាញេទិចលាតសន្ធឹងក្នុងលំហចម្ងាយប្រ-ហែលពី ពីរទៅបីដងនៃកាំផែនដីនិងមាននាទីរាំងស្ទាក់ផង់ល្អិត មានបន្ទុកអគ្គីសនីមិនឱ្យមានគ្រោះថ្នាក់ដល់ភាវៈរស់នៅ លើផែនដី ។ ត្រីវិស័យដំណើរការទៅបានក៏ដោយសារតែដែនម៉ាញេ ទិចផែនដីដែរ ។

# មេរៀនទី៣ ទម្រង់ក្នុងរបស់ផែនដី

 ៚ ☆ ៛ 

**សំណួរ១ តើអ្នកវិទ្យាសាស្ត្រដឹងពីទម្រង់ ក្នុងរបស់ផែនដីដោយវិធីណា?**

**ចម្លើយ:** អ្នកវិទ្យាសាស្ត្រដឹងពីទម្រង់ ក្នុងរបស់ផែនដីតាមរយៈការសិក្សាអំពី ភស្តុតាងនៃរញ្ជួយ និងភស្តុតាងពីសិលា ។

**សំណួរ២ ដោយផ្អែកលើលក្ខណៈរូបតើផែនដីមានប៉ុន្មានស្រទាប់? អ្វីខ្លះ ?**

**ចម្លើយ:** ដោយផ្អែកតាមលក្ខណៈរូបផែនដីមានប្រាំស្រទាប់គឺ៖

✓ មណ្ឌលថ្ម

✓ មណ្ឌលខាប់

✓ មណ្ឌលកណ្ដាល

✓ ស្នូលក្រៅ

✓ និងស្នូលក្នុង ។

**សំណួរ៣ តើសីតុណ្ហភាពនៅក្នុងជម្រៅផែនដីប្រែប្រួលដូចម្ដេច?**

**ចម្លើយ:** ស៊ីតុណ្ហភាពនៅក្នុងជម្រៅផែនដីមានការប្រែប្រួលសមាត្រទៅនឹងជម្រៅរបស់ផែនដីគឺ កាលណាជម្រៅកាន់តែជ្រៅស៊ីតុណ្ហភាពកាន់តែកើន ។ ក្នុងជម្រៅ 40m វាកើនឡើង1អង្សាសេ ។ ការកើនបែបនេះបន្តរហូតដល់ជម្រៅ 30ទៅ40 km លើសពីនេះវាកើនតិច តែថេរ ។

**សំណួរ៨ ចូរពន្យល់ភាពខុសគ្នារវាងសំបកទ្វីប និងសំបកមហាសមុទ្រ ស្នូលក្រៅ និងមណ្ឌលខាប់ ។**

**ចម្លើយ:** ភាពខុសគ្នារវាង សំបកទ្វីប និងសំបកមហាសមុទ្រ

✓សំបកទ្វីប មានសមាសធាតុផ្សំស្រដៀងនឹងសិលាក្រានីត និងមានកម្រាស់មធ្យម 30 km ។

✓សំបកមហាសមុទ្រមានសមាសធាតុផ្សំ នឹង សិលាបាសាល់ និងមានសកម្រាស់ពី 5km ដល់ 8km ។ សំបកមហាសមុទ្រធ្ងន់ជាងសំបកទ្វីបព្រោះ វាមាន សិលាបាសាល់ធ្ងន់ជាងក្រានីត ។

## ៚ ស្នូលក្រៅ និងមណ្ឌលខាប់

✓ស្នូលក្រៅ ជាស្រទាប់រាវស្ថិតនៅក្រោមម៉ង់តូ ហើយព័ទ្ធជុំ

វិញស្នូលក្នុងនិងមានកម្រាស់ប្រហែល 2 200km ។

✓មណ្ឌលខាប់ គឺជាស្រទាប់ទន់របស់ម៉ង់តូ ដែលមានបំណែកនៃមណ្ឌលថ្មធ្វើចលនាពីលើ។ វាកើតឡើងពីសិលារឹងដែលហូរយ៉ាងយឺតមានល្បឿនប្រហែលនឹងការដុះលូតលាស់នៃក្រចកដៃនិងមានកម្រាស់ប្រហែល 250 km ។

---

៤ **មេរៀនសង្ខេប**

❖ធរណីវិទូ សិក្សាពីទម្រង់របស់ផែនដីដោយផ្អែកលើ ភស្តុតាងនៃរញ្ជួយដី និងភស្តុតាងពីសិលា ។

❖សីតុណ្ហភាពនិងសម្ពាធប្រែប្រួលទៅតាម ជម្រៅនៅក្នុងដីដោយផ្អែកលើសមាសធាតុផ្សំមានបីស្រទាប់គឺ សំបក ម៉ង់តូ និងស្នូល ។ បើផ្អែកតាមលក្ខណៈរូបវិញ ផែនដីមានប្រាំស្រទាប់គឺ មណ្ឌលថ្ម មណ្ឌលខាប់ មណ្ឌលកណ្ដាល ស្នូលក្រៅ និងស្នូលក្នុង ។

# មេរៀនទី៨ ផ្លាកតិចតូនិច

សំណួរ១ តើអ្នកវិទ្យាសាស្ត្រប្រើប្រាស់ភស្តុតាងអ្វីខ្លះ ដើម្បីពន្យល់ពីការ រសាត់នៃទ្វីប ?

ចម្លើយ: អ្នកវិទ្យាសាស្ត្របានប្រើប្រាស់ភស្តុតាងដើម្បីពន្យល់អំពីការរសាត់នៃទ្វីបមានដូចជា៖

✓ភស្តុតាងផ្តោតលើលក្ខណៈពិសេសនៃដី

✓ភស្តុតាងផ្តោតលើផូស៊ីល

✓ភស្តុតាងផ្តោតលើការប្រែប្រួលនៃអាកាសធាតុ ។

សំណួរ២ ចូរពន្យល់ថា ហេតុអ្វីបានជាទ្រឹស្តីទ្វីបរសាត់របស់លោក *វេសេនី* មិនត្រូវបានគេទទួលស្គាល់ នៅលើកដំបូង ។

ចម្លើយ:បានជាទ្រឹស្តីទ្វីបរសាត់របស់លោក វេសេនី មិនបានទទួលការគាំទ្រជាលើកដំបូងពីព្រោះ ទ្រឹស្តីរបស់លោកមិនបាន ពន្យល់អំពី បុព្វហេតុដែលបណ្តាល អោយមាន ការរសាត់នៃទ្វីប គឺគាត់គ្រាន់តែសំអាងលើភស្តុតាង ដែល

បន្សល់ពីអតីតៈកាលតែប៉ុណ្ណោះ ។ ភស្តុតាងមាន ដូចជា ផូស៊ីលការប្រែប្រួលអាកាស ធាតុ និងលក្ខណៈពិសេសនៃដី ហេតុនេះទើបអ្នកវិទ្យាសាស្ត្រ មិនបានគាំទ្រ ទ្រឹស្តីរបស់លោក កាលពីលើកដំបូង ។

**សំណួរ៣ ចូរពណ៌នាពីកម្លាំងបីដែលបណ្តាលឱ្យផ្លាកតិចតូនិចធ្វើចលនា ។**

**ចម្លើយ** ពណ៌នាអំពីកម្លាំងបី ដែលបណ្តាលអោយផ្លាកតិចតូនិចមានចលនា៖

✓ **កម្លាំងទ្រនុងរុញ:** មណ្ឌលថ្ម មហាសមុទ្រត្រង់ទ្រនុងកណ្តាលមហាសមុទ្រខ្ពស់ជាងកន្លែងដែលវាលិចចុះក្រោមមណ្ឌលថ្មទ្វីប ។ កម្លាំងទ្រនុងរុញគឺជាដំណើការ ធ្វើអោយផ្លាកសមុទ្ររអិលចុះក្រោមព្រំដែនរវាងមណ្ឌលថ្មនិងមណ្ឌលខាប់ ។

✓ **កម្លាំងរង្វិល់** នៅក្នុងដំណើរការនៃរង្វិល់ រូបធាតុក្តៅចេញពីជម្រៅក្នុងផែនដីអណ្តែតឡើងលើខណៈដែល រូបធាតុត្រជាក់ជិតផ្ទៃដីលិចចុះ ។នៅពេលរូបធាតុក្តៅចុះត្រជាក់ វាក៏ក្លាយជាធ្ងន់ ហើយធ្លាក់ចុះមកក្រោម វិញ។ ចលនានៃរង្វិល់របស់រូបធាតុម៉ង់តូទាញផ្លាក តិចតូនិចឲ្យ

ឃ្លាតពីគ្នា ។

✓**កម្លាំងទំនាញនៃមណ្ឌលថ្ម:** ដោយសារមណ្ឌលថ្មមហាសមុទ្រធ្ងន់ជាងមណ្ឌលថ្មខាប់ ធ្វើឲ្យ គែម របស់ ផ្លាកមហាសមុទ្រលិចចុះ ហើយទាញផ្នែកដែលនៅសល់ របស់ផ្លាកតិតូនិចឲ្យទៅជាមួយវា ។

**សំណួរ៨ តើព្រំដែនជំនួបផ្លាទាំងបីប្រភេទខុសគ្នាដូចម្ដេចខ្លះ ?**

**ចម្លើយ:** ព្រំដែនជំនួបគ្នាទាំងបីមានលក្ខណៈខុសគ្នាដូចជា:

✓**ការទង្គិចគ្នារវាងផ្លាកទ្វីបនិងផ្លាកទ្វីប** នៅពេលផ្លាកតិចតូនិចពីរដែលជាសំបកទ្វីបប៉ះទង្គិចគ្នាផ្លាកទាំងពីរនេះប៉ោងឡើង ហើយកាន់តែក្រាស់ដោយសារការរុញឡើងនៃសំបកទ្វីប ។

✓**ការប៉ះទង្គិចគ្នារវាងផ្លាកទ្វីបនិងផ្លាកមហាសមុទ្រ:** នៅពេលផ្លាកតិចតូនិចមួយដែលជាសំបកទ្វីបទង្គិចយ៉ាងខ្លាំងជាមួយផ្លាកតិចតូនិចមួយទៀត ដែលជាសំបកមហាសមុទ្រ ធ្វើឲ្យសំបកមហាសមុទ្ររអិលចុះក្រោមសំបកទ្វីប ។ តំបន់ដែលផ្លាកមហាសមុទ្ររអិលចុះក្រោមទៅក្នុងមណ្ឌលខាប់ហៅ

ថា តំបន់ជំនួបគ្នា ។

✓**ការប៉ះទង្គិចគ្នារវាងផ្លាកទ្វីបមហាសមុទ្រ និងផ្លាកមហាសមុទ្រ:**នៅពេលផ្លាកមហាសមុទ្រពីរទង្គិចគ្នា ពេលនោះមហាសមុទ្រមួយត្រូវរអិលចុះក្រោម ផ្លាក មហាសមុទ្រមួយទៀតដូចគ្នានិងការទង្គិចគ្នារវាង ផ្លាក មហាសមុទ្រ និងផ្លាកទ្វីបដែរ ។

**សំណួរ៩ ចូរពន្យល់ពីវិធី ដែលអ្នកវិទ្យាសាស្ត្រប្រើប្រាស់ក្នុងការវាស់អត្រា រសាត់នៃផ្លាកតិចតូនិច ?**

**ចម្លើយ:** វិធីដែលអ្នកវិទ្យាសាស្ត្រប្រើប្រាស់ក្នុងការ វាស់អត្រារសាត់នៃផ្លាកតិចតូនិច ដោយការប្រើប្រាស់បណ្តាញផ្កាយរណបមានឈ្មោះថាប្រព័ន្ធកំណត់ទីតាំងលើផែនដី គឺផ្កាយរណបបានបញ្ជូនសញ្ញាណវិទ្យុឥតឈប់ឈរ ដើម្បីកំណត់ចម្ងាយឲ្យបាន ច្បាស់ជាក់លាក់មួយរវាងផ្កាយរណបនិងផែនដី ស្ថានីយលើដីមាននាទីកំណត់ពេលវេលាក្នុងពេលដំណើរការ បើកាលណាចំងាយមានការប្រែប្រួលគេនឹងទទួលបានពត៌មានអំពីការ រសាត់នៃផ្លាកតិចតូនិច ។ ដូចនេះ

អ្នកវិទ្យាសាស្ត្រអាចកំណត់ការរសាត់នៃផ្ទាំងតិចតូនិច បាន តាមរយៈការកំណត់ពេលវេលានៅស្ថានីយ៍លើដីក្នុងចម្ងាយ ជាក់លាក់មួយដោយប្រើប្រព័ន្ធសម្រាប់កំណត់ទីតាំង ។

## ៤- មេរៀនសង្ខេប

ទ្រឹស្តីទ្វីបរសាត់បានពន្យល់ពីភាពស៊ីគ្នារវាងទ្វីបអាមេរិចខាងត្បូងនិងទ្វីបអាហ្វ្រិច និងហេតុការណ៍សង្ស័យជាច្រើនទៀតផងដែរ ។ ប៉ង់ស្សៀ ជាបណ្តុំនៃទ្វីបកាលពី245លានឆ្នាំមុននិងបែកចេញពីគ្នាកាលពី 225លានឆ្នាំមុន ។

✓ភស្តុតាងគម្លាតបាតសមុទ្រ បានពីភាពបញ្ច្រាសនៃម៉ាញេទិចក្នុងបាតសមុទ្រកំអែភ្នំភ្លើង និងការខួងគំរូសិលា ។ កម្លាំងទ្រនុងរុញ ចលនាវិលវល់ និងកម្លាំងទំនាញ របស់មណ្ឌលថ្មធ្វើឱ្យផ្លាកតិចតូនិចមានចលនា ។

✓គេចែកព្រំដែនផ្លាកទិចតូនិចជាបីប្រភេទគឺព្រំដែន ជំនួបគ្នា ព្រំដែនបែកចេញពីគ្នា និងព្រំដែនជ្រួស ។ ទិន្នន័យទទួលបានពីការអង្កេតរបស់ផ្កាយរណបបង្ហា-

ញថាផ្លាកតិចតូនិចខ្លះធ្វើចលនាជាមធ្យម 3cm/ឆ្នាំ ។

# មេរៀនទី៨ ការរញ្ជួយដី

៙៙*៙៙

**សំណួរ១ តើរញ្ជួយដីកើតឡើងនៅកន្លែងណាខ្លះ ?**

**ចម្លើយ:** រញ្ជួយដី កើតឡើងនៅតាមព្រំដែនផ្លាកតិចតូនិចនៅពេលផ្លាកតិចតូនិចទង្គិចគ្នា រអិលប៉ះគ្នា ឬរសាត់ចេញពីគ្នា ។

**សំណួរ២ ចូររៀបរាប់ពីភាពខុសគ្នានៃរញ្ជួយដីតាមប្រភេទនៃចលនាផ្លាកនិង បំណាក់ស្រុត ។**

**ចម្លើយ:** ភាពខុសគ្នានៃរញ្ជួយដី តាមប្រភេទនៃចលនាផ្លាកនិងបំណាក់ស្រុតគឺ៖

- ចលនាជ្រួស: កើតឡើងនៅកន្លែង ដែលផ្លាកពីររអិលប៉ះគ្នាបង្កើតបានជាបំណាក់ស្រុតជ្រួស ។ ផ្ទាំងសំបកផែនដីរអិលប៉ះគ្នាតាមទិសផ្ដេក ហើយបណ្ដាលឲ្យមានរញ្ជួយដីមធ្យម និងរាក់ ។

- **ចលនាជំនួបគ្នា:** កើតនៅត្រង់កន្លែងផ្លាកពីររុញគ្នា ។ ចលនានេះបង្កើតឲ្យមានបំណាក់ស្រុតបញ្រ្ចាស ។ ផ្ទាំងសំបកផែនដីរុញផ្ទប់គ្នា តាមទិសបញ្ឈរតាមបណ្តោយបំណាក់ស្រុត បញ្រ្ចាស និងបណ្តាលឲ្យមានរញ្ជួយដីខ្លាំង និងជ្រៅ ។
- **ចលនាបែកចេញពីគ្នា:** កើតឡើងនៅកន្លែងផ្លាកពីរទាញគ្នា ។ លនាបែបនេះបង្កើតឲ្យមានបំណាក់ស្រុតធម្មតាផ្ទាំងសំ-បកផែនដីទាញចេញពីគ្នារអិលតាមទិសបញ្ឈរតាមបណ្តោយ បំណាក់ស្រុតធម្មតានិងបណ្តាលឲ្យមានរញ្ជួយខ្សោយ និងរាក់ ។

**សំណួរ៣ តើរលក P រលក S និងរលក L ធ្វើចលនាខុសគ្នា ដូចម្តេចខ្លះ ?**

**ចម្លើយ:** រលកP រលកS និងរលក L ធ្វើចលនាខុសគ្នាដូចជា ៖

✓ **រលកP** ជារលក ដែលមានល្បឿនលឿនជាងគេ ក្នុងចំនោមរលកទាំងអស់ ហើយជារលកទីមួយដែលមកដល់មុនគេ វាអាចឆ្លងកាត់គ្រប់ផ្នែកទាំងអស់នៃផែនដី ។

✓ រលកS ជារលកលឿនទី2 បន្ទាប់ពីរលកPវាកើកើតឡើង រួញចូលហើយត្រលប់មកទីដើមវិញ បន្ទាប់ពីខូចទ្រង់ទ្រាយ វាមិនអាចធ្វើចលនាបានគ្រប់ផ្នែកទាំងអស់នៃផែនដីទេគឺ វាមិនអាចឆ្លងកាត់រូបធាតុរាវទាំងស្រុងបានទេ ។

- រលកL ជារលកផ្ទៃលើដែលធ្វើឲ្យដីផ្លាស់ទីជារង្វង់ពេលវាធ្វើចលនាតាមផ្ទៃលើ ។វាធ្វើចលនាយឺតជាងរលកទាំងពីរខាងលើតែវាបំផ្លាញខ្លាំងនៅពេលមានរញ្ជួយ ព្រោះវាអង្រួនដីតាមទិសបញ្ឈរ ។

សំណួរ៤ **តើរលកស៊ូណាមិ នៅមហាសមុទ្រឥណ្ឌាឆ្នាំ ២០០៤ កើតឡើង ដូចម្តេចនិងបានបំផ្លាញអ្វីខ្លះ ?**

**ចម្លើយ:** រលកស៊ូណាមិនៅមហាសមុទ្រឥណ្ឌាឆ្នាំ 2004 បានកើតឡើងដោយសាររញ្ជួយដី ក្នុងបាតសមុទ្របណ្តាលឲ្យកក្រើកបាតសមុទ្រនិងរុញទឹកសមុទ្រឲ្យមានចលនាជារលកធំៗ ។ រលកនេះបានសាយចេញពីផ្ចិតលើនៃកន្លែងរញ្ជួយដីកាត់ផ្ទៃ មហាសមុទ្រកម្ពស់រលកនេះទាប នៅកណ្តាលសមុទ្រ ប៉ុន្តែ ពេលវាធ្វើចលនាដល់កន្លែងដែលមានទឹករាក់

រលកប្រែជាមាន ទំហំប៉ុនៗភ្នំ ។ រលកនេះបានបំផ្លាញជីវិតមនុស្សអស់ចំនួន 225 000នាក់ដែលរស់នៅក្នុងប្រទេសចំនួន11 និងបានបំផ្លាញទ្រព្យសម្បត្តិច្រើនមហិមា ដូចជាផ្ទះសំបែង ផ្លូវថ្នល់ កំពង់ផែ និងអគារ ពាណិជ្ជកម្ម ជា ច្រើនទៀត ។

**សំណួរ៨ តើអ្នកគួរធ្វើដូចម្តេចខ្លះដើម្បីការពារសុវត្ថិភាពពេលមាន រញ្ជួយដី?**

**ចម្លើយ:** ដើម្បីការពារសុវត្ថភាពពេលមានរញ្ជួយដីយើងត្រូវ៖

- **មុនពេលរំញ័រចាប់ផ្តើម** ជួបជុំគ្នាដើម្បីរៀបចំគំរោងការការពារពេលមានរញ្ជួយក៏ដូចជាការប្រកាស់ដំណឹងឲ្យបានដឹង ពីរញ្ជួយដីថានឹងជិតមកដល់ ។
- **នៅពេលរំញ័រចាប់ផ្តើម** រកវិធីសាស្ត្របែបណាដើម្បីជៀសឲ្យផុតពីគ្រោះថ្នាក់បណ្តាលមកពីរញ្ជួយដីដូចជា ត្រូវក្រាប ឬផ្កាប់មុខចុះក្រោមនៅកណ្តាលបន្ទប់និងមួយទៀតបើកំពុងស្ថិតនៅក្នុងរថយន្តលើផ្លូវគួរតែ បញ្ឈប់រថយន្ត

ហើយកុំចាក ចេញពីរថយន្តជាដើម ។

➢ **បន្ទាប់រញ្ជួយដីបានបញ្ចប់** នៅពេលនោះ យើងម្នាក់ៗ តែងតែមានភាពភ័យខ្លាចយើងគួរតែ តាំងអារម្មណ៍ឲ្យស្ងប់ និងរៀបចំគំរោងការដោះស្រាយនូវអ្វីដែលបានបាត់បង់ និង ខូចខាត ។ យើងមិនត្រូវធ្វេសប្រហែសនឹងអ្វី ដែលជារបស់ សំណល់សល់ពីរញ្ជួយដីព្រោះវាអាចបណ្តាល ឲ្យមានគ្រោះ ថ្នាក់ដូចជាកន្លែងមានភ្លើងឆេះកញ្ចក់បែកនិងអគារ ដែលមាន លក្ខណៈខូចខាតច្រើនព្រោះវាអាចមានការដួលរលំ ឬ ក៏អាច មានរញ្ជួយដីម្តងទៀតក្នុងខណៈ ពេលជាប់គ្នានេះ ។

**សំណួរ៥** ប្រសិនបើបរិមាណថាមពលបញ្ចេញដោយ រញ្ជួយដីមួយ ដែលមានកម្លាំង2.0រិចទ័រស្មើ នឹងn ។ តើបរិមាណថាមពលដែលប ញ្ចេញ ដោយ 3.0 4.0 5.0 6.0រិចទ័រ ត្រូវជាប៉ុន្មាន n ។

**ចម្លើយ** រកបរិមាណថាមពលដែលបញ្ចេញដោយរញ្ជួយដីកើន ឡើងតាមពហុគុណនៃ n

✓**ករណីមានកម្លាំង** 3.0 4.0 5.0 6.0 រិចទ័រ

ដោយ 2 រិចទ័រស្មើនឹង n

តាមគោលការណ៍សមាមាត្រ

$$\Rightarrow 3.0 \text{ រិចទ័រ } = \frac{3n}{2} = 1.5n$$

$$\Rightarrow 4.0 \text{ រិចទ័រ } = \frac{4n}{2} = 2n$$

$$\Rightarrow 5.0 \text{ រិចទ័រ } = \frac{5n}{2} = 2.5n$$

$$\Rightarrow 5.0 \text{ រិចទ័រ } = \frac{6n}{2} = 3n$$

## ៧ *មេរៀនសង្ខេប*

- រញ្ជួយដី កើតឡើងនៅតាមព្រំដែនផ្លាកតិចតូនិចនៅពេលផ្លាកតិចតូនិចទង្គិចគ្នា រអិលប៉ះគ្នា ឬរសាត់ចេញពីគ្នា ។ សិលានៅតាមបណ្តោយស្នាមប្រេះមានលក្ខណៈពីរយ៉ាងគឺលក្ខណៈប្លាស្ទិចនិងលក្ខណៈយឺត ។ កំហូចទ្រង់ទ្រាយក្នុងលក្ខណៈយឺតបណ្តាលឲ្យស្រទាប់សិលារួញចូលហើយរលោស់បង្កើតបានជារញ្ជួយដី ។ គេចែករញ្ជួយដីជាបីប្រភេទ គឺ*រលកP រលកS* និង *រលកL* ។ រលករញ្ជួយដីទាំងបីនេះធ្វើចលនាខុសៗគ្នា

កាត់ផែនដី។ រញ្ជួយរិទូ ប្រើប្រាស់ក្រាបរញ្ជួយដី ដើម្បីកំណត់ ពេលវេលានិងទីកន្លែងដែលវាកើតឡើង។ គេប្រើមាត្រ ដ្ឋានរិចផ្ទ័រនិងមែកាលី ដើម្បីវាស់កម្លាំងនិងអត្រាបំផ្លា- ញនៃរញ្ជួយដី ។

- មូលហេតុដែលបណ្តាលឲ្យមានការបំផ្លាញរួមមានការអង្រួនដី ភក់ភាវ រំញ័របន្ទាប់ និងរលកស៊ូណាមិ។

ដើម្បីការពាររញ្ជួយដី អ្នកត្រូវមានការរៀបចំគម្រោងចាប់តាំងពីមុនពេលរញ្ជួយដីក្នុងពេលរញ្ជួយដី និងក្រោយពេលរញ្ជួយដីបានបញ្ចប់ ។

# មេរៀនទី៦ ភ្នំភ្លើង

លល☆លល

សំណួរ១ តើភ្នំភ្លើងច្រើនកើតនៅកន្លែងណាខ្លះនៃផ្ទៃផែនដី?

ចម្លើយ: ភ្នំភ្លើងកើតឡើងនៅតាមព្រំដែនជំនួបគ្នាព្រំដែនបែកចេញនៃ ផ្លាកតិចតូនិច និងលើចំនុចក្តៅនៃផែនដី។

**សំណួរ២ តើមន្ទុះភ្នំភ្លើងស្ងប់បង្កើតកំអែភ្នំភ្លើង ឬបំណែកសិលាភ្នំភ្លើង? ចូរពន្យល់ ។**

ចម្លើយ: បន្ទុះភ្នំភ្លើងស្ងប់បង្កើតបានកំអែភ្នំភ្លើងពីព្រោះវា បានបញ្ចេញទន្លេកំអែភ្នំភ្លើងយ៉ាងស្ងៀមស្ងាត់បង្កើតបាន បរិមាណសិលា នៃកំអែភ្នំភ្លើងយ៉ាងច្រើនមកលើផ្ទៃដី ។

**សំណួរ៣ ប្រសិនបើម៉ាក់មានៃភ្នំភ្លើងមួយមានសមាមាត្រទឹក និងស៊ីលីកាច្រើនតើអ្នកព្យាករណ៍ថាវាជាបន្ទុះភ្នំភ្លើងខ្លាំងឬបន្ទុះស្ងប់? ហេតុអ្វី ?**

ចម្លើយ: ប្រសិនបើម៉ាក់ម៉ានៃភ្នំភ្លើងមួយមានសមាមាត្រ ទឹក

និងស៊ីលីកាច្រើនវានឹងបណ្តាលឲ្យមានបន្ទុះខ្លាំង ព្រោះកាលណា មានស៊ីលីកានឹងទឹកច្រើន វានឹងធ្វើឲ្យម៉ាក់ម៉ាមានកំហាប់ធាតុរាវតិចចំណែកម៉ាក់ម៉ាច្រើនខាប់ជាហេតុ ធ្វើអោយវាមិនអាចហូរចេញមកក្រៅតាមសំរួលបាន គឺស្ទះបំពង់មាត់ភ្នំភ្លើង កាលណាវាមានការរងសម្ពាធកាន់តែខ្លាំងវានឹងផ្ទុះបានជា បន្ទុះខ្លាំង ។

**សំណួរ៤** ចូររៀបរាប់ពីប្រភេទសណ្ឋានដីភ្នំភ្លើងសំខាន់ៗទាំង៤ ។

**ចម្លើយ:** ប្រភេទសណ្ឋានដីភ្នំភ្លើងសំខាន់ៗទាំងបីមាន៖

✓ **ភ្នំភ្លើងខែល** វាកើតពីស្រទាប់កំអែភ្នំភ្លើង ដែលហូរគ លើគ្នាជាបន្តបន្ទាប់បន្ទុះស្ងប់ ។ ដោយសារកំអែមាន លក្ខណៈរាវខ្លាំង ធ្វើឲ្យរាលដាលគ្របដណ្តប់លើផ្ទៃដីធំ ។ នៅទីបំផុត វាបង្កើតបានជាភ្នំភ្លើងខែលដែលមានចំណោទទេ និង ទាប ។

✓ **ភ្នំភ្លើងសាជី** ភ្នំភ្លើសាជីមានរាងសាជីតូចៗដែលកើតឡើងពីបំណែកសិលានៃបន្ទុះធន់កណ្តាល បំណែកសិលា បង្កើតបានជាចំណោតចោតខ្លាំងនិងមានបាតតូចជាងភ្នំភ្លើងខែល ។

✓ ភ្នំភ្លើងសមាស ភ្នំភ្លើងសមាសកើតពីបន្ទុះឆ្លាស់គ្នានៃបន្ទុះស្ងប់និងបន្ទុះខ្លាំង ។ បន្សំនៃកំអែភ្នំភ្លើងបង្កើតបានជាស្រទាប់សិលាឆ្លាស់គ្នា ។ វាមានបាតធំចំណោតមធ្យម និងមានកម្ពស់ខ្ពស់ ។

✓ ខ្ពង់រាបកំអែភ្នំភ្លើង វាលទ្ធផលនៃលំហូរកំអែភ្នំភ្លើងរាវហូរចេញពី ស្នាមប្រេះបែកជាច្រើននៃបន្ទុះស្ងប់ដែលគ្របដណ្តប់លើដីរាប់ពាន់គីឡូម៉ែតការេ ។

**សំណួរ៨ ពណ៌នាពីភស្តុតាងដែលបញ្ជាក់ថាប្រទេសកម្ពុជាធ្លាប់មានភ្នំភ្លើងផ្ទុះពីអតីតកាល ។**

**ចម្លើយ** គេបានសង្កេតឃើញភស្តុតាងជាច្រើន ដែលបញ្ជាក់ថាប្រទេសកម្ពុជា មានការផ្ទុះនៃភ្នំភ្លើងជាច្រើនកាលពី សម័យមុន ។ គេបានសង្កេតឃើញ មាត់ភ្នំភ្លើងចាស់នៅ ខេត្តរតនគីរី ( បឹងយក្សឡោម ) ខ្ពង់រាបដីក្រហមខេត្ត កំពង់ចាមគឺជា លទ្ធផលនៃកំអែភ្នំភ្លើងរងការពុកផុយជា ច្រើនលានឆ្នាំ និងមានកន្លែងជាច្រើនទៀត ដែលបញ្ជាក់ថាប្រទេសកម្ពុជាមានការបន្ទុះភ្នំភ្លើងជាច្រើនកាលពីសម័យមុន ។

## ៦ មេរៀនសង្ខេប

➢ ភ្នំភ្លើងកើតឡើងនៅតាមព្រំដែនជំនួបគ្នាព្រំដែនបែកចេញនិងលើចំនុចក្ដៅ។ ភ្នំភ្លើងអាចផ្ទុះខ្លាំងឬស្ងប់អាស្រ័យ នឹងកំហាប់ ស៊ីលីកា ទឹក និងឧស្ម័ននៅក្នុងម៉ាក់ម៉ា ។ បន្ទុះស្ងប់បញ្ចេញកំអែ ចំណែកបន្ទុះខ្លាំងបញ្ចេញបំណែក សិលា ។ ភ្នំភ្លើងខែលភ្នំភ្លើងសាជីភ្នំភ្លើងសមាស និងខ្លង់ រាបកំអែភ្លើងគឺជាសណ្ឋានដីភ្នំភ្លើង ។

➢ បច្ចុប្បន្នប្រទេសកម្ពុជាពុំមានភ្នំភ្លើងផ្ទុះទេប៉ុន្តែគេឃើញភស្តុតាង ដែលបញ្ជាក់ថាប្រទេសកម្ពុជាមានភ្នំ ភ្លើងផ្ទុះនៅអតីតកាល ។

# សំណួរបញ្ចប់ជំពូក១

I. ចូរគូសញ្ញា ✓ នៅមុខចម្លើយត្រឹមត្រូវ

1) ភពផែនដីកើតឡើងប្រហែល

☐ ក. 3000លានឆ្នាំមុន

☐ ខ. 700លានឆ្នាំមុន

☐ គ. ប្រហែល4000លានឆ្នាំមុន

☐ ឃ. ប្រហែល4600លានឆ្នាំមុន

2) អ្នកវិទ្យាសាស្ត្រដែលបានលើកអំណះអំណាងស្តីអំពីផែនដីមានរាងស្វ៊ែមុនគេ

☐ ក. លោកអឺរ៉ាតូស្តែន ☐ ខ.លោកអារីស្តូត

☐ គ. លោកវេសេនឺ ☐ ឃ. លោកហេស

3) ដែនម៉ាញេទិចផែនដីកើតឡើងពីរង្វិលខ្វាល់និង

☐ ក. រង្វល់នៃស្នូលក្រៅ

☐ ខ. រង្វល់នៃមណ្ឌលខាប់

☐ គ. រង្វល់នៃម៉ង់តូ

☐ ឃ. រង្វល់នៃស្នូលក្នុង

II. ចូរបំពេញល្បះខាងក្រោមឲ្យបានត្រឹមត្រូវ

1) ប៉ង់សៀជាបណ្តុំនៃទ្វីបកាលពី..........ឆ្នាំមុននិងបែកចេញពីគ្នាកាលពី........... ឆ្នាំមុន ។

2) កម្លាំងទ្រនុងរុញ......... និងកម្លាំង........... ធ្វើឲ្យផ្លាកតិចតូនិចមានចលនា។

3) រញ្ជួយដី កើតឡើងនៅតាមព្រំដែនផ្លាកតិចតូនិចនៅពេលផ្លាក......... ......... .......... ។

4) គេចែករញ្ជួយដីជាបីប្រភេទ គឺរលក ......... រលក ...... និងរលក .............. ។

5) ភ្នំភ្លើងអាចផ្ទុះខ្លាំងឬស្ងប់អាស្រ័យនឹង.........និង..... ...ដែលមាននៅក្នុងម៉ាក់ម៉ា ។

III. ចូរផ្គូផ្គងផ្នែក A និង B រួចភ្ជាប់ចម្លើយត្រូវក្នុងផ្នែកC

| A | B | C |
|---|---|---|
| 1. បន្ទុះស្ងប់បញ្ចេញ | .ភ្នំភ្លើងសមាស | → |
| 2. រង្វាស់កម្លាំងរញ្ជួយដីគឺ | ខ. មាត្រដ្ឋានមេកា លី | → |
| 3. ភ្នំភ្លើងដែលកើតពីស្រទាប់ | គ. កំអែភ្នំភ្លើង | → |

| | | |
|---|---|---|
| ឆ្លាស់គ្នារវាង កំអែភ្នំភ្លើងនិងបំណែកសិលាភ្នំភ្លើងគឺ | ឃ.បំណែកសិលាភ្នំភ្លើង<br>ង. មាត្រដ្ឋានរិចឆ្ន័រ | |

ᨀᨁ☆ᨀᨂ

# ចម្លើយបញ្ចប់ជំពូក១

I. ចូរគូសសញ្ញា ✓ នៅមុខចម្លើយត្រឹមត្រូវ

1) ភពផែនដីកើតឡើងប្រហែល

☐ ក..3000លានឆ្នាំមុន

☐ ខ. 700លានឆ្នាំមុន

☐ គ. ប្រហែល4000លានឆ្នាំមុន

☑ **ឃ. ប្រហែល4600លានឆ្នាំមុន**

2) អ្នកវិទ្យាសាស្ត្រដែលបាន លើកអំណះអំណាងស្ដីអំពីផែនដីមានរាងស្វ៊ែមុនគេ

☐ ក. លោកអ៊ីរ៉ាតូស្ដែន ☑ **ខ.លោកអារីស្តូត**

☐ គ. លោកវេសេនី ☐ ឃ. លោកហេស

3) ដែនម៉ាញេទិចផែនដីកើតឡើងពីវង្វិលខ្វាល់និង

☑ ក. វង្វល់នៃស្នូលក្រៅ

☐ ខ. វង្វល់នៃមណ្ឌលខាប់

☐ គ. វង្វល់នៃម៉ង់តូ

☐ ឃ. វង្វល់នៃស្នូលក្នុង

II. ចូរបំពេញល្បះខាងក្រោមឲ្យបានត្រឹមត្រូវ

1) ប៉ង់សៀជាបណ្តុំនៃទ្វីបកាលពី 245លាន ឆ្នាំមុននិង បែកចេញពីគ្នាកាលពី 25លាន ឆ្នាំមុន ។

2) កម្លាំងទ្រនុងរុញកម្លាំងវង្វល់ និងកម្លាំង ទំនាញនៃមណ្ឌលថុម ធ្វើឲ្យផ្លាកតិចតូនិចមានចលនា។

3) រញ្ជួយ ដីកើតឡើងនៅតាមព្រំដែនផ្លាកតិចតូនិចនៅ ពេលផ្លាក ទង្គិចគ្នា រអិលប៉ះគ្នា ឬរសាត់ចេញពីគ្នា ។

4) គេចែករញ្ជួយដីជាបីប្រភេទ គឺរលក P រលក S និងរលក L ។

5) ភ្នំភ្លើងអាចផ្ទុះខ្លាំងឬស្ងប់អាស្រ័យនឹង ស៊ីលីកា និង

ទឹក ដែលមាននៅក្នុងម៉ាក់ម៉ា ។

III. ចូរផ្គូផ្គងផ្នែក A និង B រួចភ្ជាប់ចម្លើយត្រូវក្នុងផ្នែកC

| A | B | C |
|---|---|---|
| 1.បន្ទុះស្ងប់បញ្ចេញ | ក.ភ្នំភ្លើងសមាស | 1→គ |
| 2. រង្វាស់កម្លាំងរញ្ជួយដីគឺ | ខ.មាត្រដ្ឋានមេកាលី | 2→ង |
| 3. ភ្នំភ្លើងដែលកើតពីស្រទាប់ឆ្លាស់គ្នារវាងកំអែភ្នំភ្លើងនិងបំណែកសិលាភ្នំភ្លើងគឺ | គ. កំអែភ្នំភ្លើង<br>ឃ.បំណែកសិលាភ្នំភ្លើង<br>ង. មាត្រដ្ឋានរិចស្ទ័រ | 3→ក |

## ជំពូក២ ទឹកនៅលើទពផែនដី

## មេរៀនទី១ វដ្តទឹក

ଓ☆ଓ

**សំណួរ១ តើវដ្តទឹកមានប៉ុន្មានដំណាក់កាល ? អ្វីខ្លះ?**

ចម្លើយ: វដ្តទឹកមានបីដំណាក់កាលគឺ

- ➢ រំហួត
- ➢ កំណាក
- ➢ កំណាកអាកាស ។

**សំណួរ២ ចូរពន្យល់ពីដំណាក់កាលនៃវដ្តទឹក ដែលទឹកធ្វើចលនាចូលក្នុងមណ្ឌលអាកាស ។**

ចម្លើយ: ដំណាក់កាលនៃវដ្តទឹកដែលធ្វើចលនាចូលក្នុងមណ្ឌលអាកាសគឺ៖

- ✓ រំហួត គឺការកែប្រែទឹករាវនៅលើផែនដីឲ្យទៅជាឧស្ម័ន គឺក្លាយជាចំហាយទឹកដែលអាចនាំយកទៅមណ្ឌលអាកាសបាន ។
- ✓ កំណាក ដំណើរនៃការកែប្រែចំហាយទឹកដែលនាំពីលើដី

ទៅក្នុងមណ្ឌលអាកាស តាមរយៈខ្យល់ក្តៅ ។ ពេលចំហាយទឹកបានជួបជាមួយភាគល្អិតនៃធូលីតូចៗ ឬផ្សែងដែលមាននាទីជា ស្នូលបង្កើតបានជាពពកក្នុងមណ្ឌលអាកាស ។ តំណក់ចំហាយទឹកកាន់តែធំនៅក្នុងកំណក់អាកាស កាលណាចំហាយទឹកកាន់តែ ច្រើន បណ្តាលឲ្យមានមាឌទឹក ។

✓កំណកអាកាស កាលណាមាឌទឹកកាន់តែធំមានកំណកកាន់តែធំ ហើយចរន្តខ្យល់បានបក់បោក ធ្វើឲ្យពពកផ្លាស់ទី បន្ទាប់មកដំណក់ទឹកដែលមានទំងន់ធំក៏ធ្លាក់មកផែនដីក្រោម រូប ភាពជាភ្លៀង ព្រិល ភ្លៀងលាយព្រិល ហើយវាបាន ហូរចូលក្នុងប្រភពទឹកនៅលើផែនដីរួចរងនូវរំហួតជាបន្តបន្ទាប់ ទៀត ។

**សំណួរ៣ ចូរចុះបញ្ជីប្រភពទឹកសំខាន់ៗ នៅលើភពផែនដី ។**

**ចម្លើយ:** ប្រភពទឹកសំខាន់ៗនៅលើផែនដីមាន

➢ ទឹកសាបសម្រាប់ប្រើប្រាស់ ដូចជា ទឹកស្ទឹង បឹងទន្លេ និងទឹកក្រោមដី គឺសម្រាប់មនុស្សនិងរុក្ខជាតិសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃ ។ទឹកសាបសំរាប់ការបំរើឲ្យវិស័យទេសចរណ៍

ដូចជា ទឹកជ្រោះ ទន្លេ បឹងធម្មជាតិ និងខ្លះទៀត បានប្រើប្រាស់សម្រាប់ជាទំនប់វារីអគ្គិសនីផ្តល់ភាពងាយស្រួល ដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

-➢ ទឹកសមុទ្រសម្រាប់ប្រើប្រាស់ជាវិស័យទេសចរណ៍ និង ឧស្សាហកម្ម ដូចជា រ៉ែ និងឧស្ម័នជាដើម ។

**សំណួរ៤ តើប្រភពទឹកសាបណាខ្លះដែលមានសារៈសំខាន់បំផុតសម្រាប់មនុស្ស សត្វ និងរុក្ខជាតិ ចូរលើកឧទាហរណ៍ជាក់ស្តែង ?**

**ចម្លើយ:** ទឹកសាបដែលមានសារៈសំខាន់បំផុតសំរាប់មនុស្សសត្វ និងរុក្ខជាតិមានដូចជា ទឹកស្ទឹង បឹងទន្លេ និងទឹក ក្រោមដី។

**ឧទាហរណ៍:**

➢ សំរាប់ការប្រើប្រាស់ជាប្រចាំថ្ងៃរបស់ មនុស្ស សត្វ និង និងរុក្ខជាតិដូចជា ហូប ដាំស្ល និងការប្រើប្រាស់សម្រាប់ការលូតលាស់របស់រុក្ខជាតិ... ។

➢ សំរាប់វិស័យកសិកម្ម ដំនាំស្រូវ ពោត សណ្តែកជាដើម

➢ ប្រើប្រាស់សំរាប់វិស័យទេសចរណ៍ ទឹកជ្រោះ បឹងធម្មជាតិ ,... ។

➤ ប្រើប្រាស់សំរាប់វិស័យឧស្សាហកម្ម ទំនប់វារីអគ្គិសនី និងជំនីកយករ៉ែជាដើម ។

➤ ការប្រើប្រាស់សំរាប់វិស័យគមនាគមន៍ គឺមានភាពងាយ ស្រួលក្នុងការធ្វើដំណើរមានតំលៃថោកមានការសន្សំ សំចៃខ្ពស់ និងលឿនរហ័ស ។

## ៤- មេរៀនសង្ខេប

➤ វដ្តទឹក គឺជាចលនាឥតឈប់ឈរនៃទឹកពីប្រភពដូចជា បឹង ទន្លេ ស្ទឹង សមុទ្រ មហាសមុទ្រលើដី និង ក្នុងដីចូល ទៅក្នុងមណ្ឌលអាកាសបង្កើតបានជា កំណក រួចធ្លាក់ ត្រឡប់ចូលទៅកាន់ប្រភពដើមវិញ ។

➤ វដ្តទឹកមានបីដំណាក់កាលគឺ រំហួត កំណកនិងកំណកអាកាស ។

➤ ភពផែនដីត្រូវបានគេដាក់ឈ្មោះឲ្យជាប្រភពទឹកឬភពពណ៌ខៀវ ដោយសារតែមានទឹកគ្របដណ្តប់70%នៃផ្ទៃ ភពទាំងមូល ។ ប៉ុន្តែ 97%នៃទឹកទាំងអស់ជាទឹកប្រៃ មានតែប្រហែល 3%ដែលជាទឹកសាបហើយក្នុងនោះទឹកសំរាប់ប្រើប្រាស់មាន

តែ មួយភាគតូចតែប៉ុណ្ណោះដែលស្ថិតនៅក្នុងបឹង ទន្លេ ស្ទឹង និងទឹកក្នុងដី ។

# មេរៀនទី២ ទឹកសាប

**សំណួរ១ តើទឹកសាបដែលមនុស្សយើងប្រើប្រាស់មានប្រភពមកពីណា ?**

ចម្លើយ: ទឹកសាបដែលមនុស្សប្រើប្រាស់មានប្រភពមកពី ទឹកក្រោមដី និងទឹកលើផ្ទៃដី មានដូចជា បឹង ស្ទឹង ទន្លេ និងអណ្តូងជាដើម ។

**សំណួរ២ តើនីវ៉ូទឹកក្នុងដីជាអ្វី ?**

ចម្លើយ: នីវ៉ូទឹកក្នុងដី ជាតំបន់ពីជួបគ្នាបង្កើតបានជាព្រំដែនទឹកក្នុងដី ។

**សំណួរ៣ ចូរពន្យល់ពីលំនាំដែលបង្កើតឱ្យមានអណ្តូងទឹកផុស ។**

ចម្លើយ: លំនាំដែលបង្កឲ្យមានអណ្តូងទឹកផុសមានគឺ បណ្តាលមកពីកន្លែងដែលមានស្នាមប្រេះដោយធម្មជាតិនៅក្នុង ស្រទាប់

សិលាគម្រប ។ ស្រទាប់សិលានេះសង្កត់ទឹកនៅក្នុង ជង្ហើម ទឹកឲ្យទឹកហូរចេញមកក្រៅតាមស្នាមប្រេះ បង្កើតបានជា អណ្តូងទឹកផុស ។

**សំណួរ៤ ទន្លេមេគង្គនិងទន្លេសាបបានផ្តល់នូវសក្តានុពលភាពយ៉ាង ច្រើនដល់ប្រទេសកម្ពុជា តើសក្តានុពលទាំងនោះមានអ្វីខ្លះ ?**

**ចម្លើយ:** ទន្លេមេគង្គនិងទន្លេសាបបានផ្តល់សក្តានុពលភាពដល់ ប្រទេសកម្ពុជាជាច្រើនដូចជា:

❖ ទន្លេមេគង្គ បានហូរនាំដីល្បាប់ដ៏មានជីជាតិសំរាប់ កសិកម្ម ជាប្រភព ទឹក សំរាប់ចិញ្ចឹមប្រជាជនកម្ពុជាមួយផ្នែក ហើយវាបាន បម្រើដល់វិស័យគមនាគមន៍ប្រព័ន្ធគមនាគមន៍ បានយ៉ាងប្រសើរ ម្យ៉ាងទៀតវាបានផ្តល់នូវមច្ឆាជាតិជាប្រភព ប្រូតេអ៊ីនយ៉ាងប្រសើរ សម្រាប់ប្រជាជនកម្ពុជា ។

❖ ទន្លេសាប ជាប្រភពនៃការនេសាទ វាបានផ្តល់នូវការ នេសាទដល់ប្រជាជន ក្នុងការរកប្រាក់ចំណូលបានមកពីការនេ សាទ ព្រោះវាជាប្រភពត្រីយ៉ាងច្រើនក្រៃលែង មិនតែប៉ុណ្ណោះ វាបានផ្តល់ទឹកសម្រាប់ការធ្វើកសិកម្មផងដែរ ។

## ☛ មេរៀនសង្ខេប

➢ បរិមាណទឹកសាបដែលមាន ហើយអាចប្រើប្រាស់បាន នៅលើផែនដីមានកំណត់ ។ ទឹកសាបមានពីប្រភេទគឺ **ទឹកលើផ្ទៃដី** និង**ទឹកក្រោមដី** ។ ប្រមាណ **95%** នៃទឹកសាបក្នុងរូបភាពរាវនៅលើពភពលោកជា ទឹកក្នុងដី ។

➢ ជលសាស្ត្រប្រទេសកម្ពុជាកំណត់ដោយ ប្រព័ន្ធទន្លេសាប និងទន្លេមេគង្គ ។ ប្រព័ន្ធទន្លេមេគង្គរួមមានទន្លេមេគង្គ ទន្លេតូច ទន្លេបាសាក់ និងដៃរបស់វា ។ ទន្លេមេគង្គ ហូរកាត់ប្រទេសកម្ពុជាប្រវែង **500km** ពីជើង ទៅត្បូង ហើយជាទន្លេវែងជាងគេទី 12 នៅលើពិភពលោក ។

➢ ប្រព័ន្ធទន្លេសាបរួមមាន **បឹងទន្លេសាប ទន្លេសាប និងដៃរបស់វា** ។ បឹងទន្លេសាបជាបឹងមានទំហំធំជាងគេបង្អស់ នៅភូមិ **ភាគអាស៊ីអាគ្នេយ៍** ។

## មេរៀនទី៣ សមុទ្រនិងមហាសមុទ្រ

**១០០☆០០២**

**សំណួរ១ ចូរអធិប្បាយពីដំណើរការកកើតមហាសមុទ្រដំបូង ?**

**ចម្លើយ:** មហាសមុទ្រដំបូងកកើតឡើងពីការវិវត្តនៃបរិយាកាស ដែលបានចុះត្រជាក់សមល្មម ដែលអាចឲ្យចំហាយទឹក ក្លាយជាកំណាក ហើយធ្លាក់មកជាភ្លៀងហើយទឹកភ្លៀងបានចាប់ផ្ដើមចាក់បំពេញ តំបន់មានកំហូងនិងទំនាបនៃ ភពផែនដីរហូតពេញ ក្លាយជាមហា សមុទ្រជាលើកដំបូង នៅលើភពផែនដី ។

**សំណួរ២ ចូររៀបរាប់ឈ្មោះមហាសមុទ្រទាំងបួន ព្រមទាំងទ្វីបដែលនៅជាប់ ។**

**ចម្លើយ:** មហាសមុទ្រនៅលើពិភពលោកទាំងបួនមាន

- មហាសមុទ្រប៉ាស៊ីភិច មានព្រំដែនខាងកើតជាប់ទ្វីប អាមេរិចនិងខាងលិចជាប់នឹងទ្វីបអាស៊ីនិងអូស្ត្រាលី ។
- មហាសមុទ្រអាកទិច មានព្រំប្រទល់ព័ទ្ធជុំវិញដោយ ទ្វីបអឺរ៉ាស៊ីនិងអាមេរិចខាងជើង ។

➤ មហាសមុទ្រអាត្លង់ទិច មានព្រំដែនខាងលិចជាប់នឹងទ្វីបអាមេរិច ខាងកើតជាប់នឹងទ្វីប អឺរ៉ាស៊ី និងអាព្រិច ។

➤ មហាសមុទ្រឥណ្ឌា មានព្រំដែនខាងលិចជាប់ទ្វីបអាព្រិច ខាងកើតជាប់ឧបទ្វីបឥណ្ឌូចិន ខាងលិច ជាប់ជាមួយទ្វីបអង់តាកទិចនិងអូស្ត្រាលី ។

**សំណួរ៣ ចូររៀបរាប់ពីក្រុមជីវិតទាំងបីនៅក្នុងមហាសមុទ្រ ព្រមទាំងផ្តល់ ឧទាហរណ៍, ។**

**ចម្លើយ:** ក្រុមជីវិតទាំងបីនៅក្នុងមហាសមុទ្ររួមមាន

➤ ប្លង់តុង គឺជាសារពាង្គកាយដែលអណ្តែតលើ ឬក្បែរផ្ទៃលើមហាសមុទ្រ ។ វាចែកជាពីគឺ ប្លង់តុងសត្វ និងប្លង់តុងរុក្ខជាតិ ។

➤ ណិកតុង គឺសារពាង្គកាយដែលហែលដោយសេរីនៅក្នុងសមុទ្រ ។ វាមានដូចជា ត្រីបាឡែនត្រីដូហ្វីន និងត្រី ជាច្រើនប្រភេទទៀត ។

➤ បង់តូស គឺសារពាង្គកាយដែលរស់នៅលើ ឬនៅក្នុងបាតសមុទ្រ ។ វាមានដូចជា ក្តាម ផ្កាថ្ម ឈ្លើង

ផ្កាយសមុទ្រ... ។

**សំណួរ៤ ហេតុអ្វីបានជាទឹកសមុទ្រនៅតំបន់ឆ្នេរដែលក្តៅ ហើយស្ងួតមានកម្រិតភាពប្រៃខ្ពស់ជាងទឹកសមុទ្រដែលនៅតំបន់ឆ្នេរត្រជាក់ហើយសើម? ចូរពន្យល់ ។**

<u>ចម្លើយ</u>ប្រភេទធនធានធម្មជាតិបួនដែលបានមកពីសមុទ្រមាន៖

- ប្រេងកាត
- ឧស្ម័នធម្មជាតិ
- អាហារ ( ត្រី ក្តាម អំបិល... )
- ម៉ង់កាណែស ទង់ដែង នីកែល ... ។

**សំណួរ២ ចូររាប់ប្រភេទធនធានធម្មជាតិពីមហាសមុទ្រយ៉ាងតិចឱ្យបានបួន ។**

<u>ចម្លើយ:</u> ប្រភេទធនធានមហាសមុទ្រមាន៖

សារាយសមុទ្រផ្កាថ្ម ត្រីបាឡែន ត្រីដូហ្វិន ក្តាមសមុទ្រ.......។

## មេរៀនសង្ខេប

➢ មហាសមុទ្រចែកជាបួនធំៗគឺ មហាសមុទ្រប៉ាស៊ីភិច អាត្លង់ទិច ឥណ្ឌា និងអាកទិច ។

➢ កម្រិតជាតិប្រៃនៃសារធាតុរាវ. ជាបរិមាណសរុបនៃអំបិលដែលរលាយ និងសារធាតុរឹងផ្សេងទៀតក្នុងបរិមាណណាមួយនៃសារធាតុរាវនោះ ។ ជាមធ្យមទឹកមហាសមុទ្រមានកម្រិតជាតិប្រៃ 39 ភាគពាន់ ។

➢ ដោយយោងទៅលើសីតុណ្ហភាពទឹក គេចែកទឹកមហាសមុទ្រជាបីគឺ តំបន់ផ្ទៃលើ តំបន់សីតុណ្ហភាពធ្លាក់ចុះខ្លាំង និងតំបន់ជ្រៅ។ សារពាង្គកាយមហាសមុទ្រចែកជាបីក្រុមសំខាន់គឺ ប្លង់តុង ណិកតុង និងបង់តូស ។

➢ បរិស្ថានមហាសមុទ្រសំខាន់មានពីរគឺ មជ្ឈដ្ឋានបង់ទិច និងមជ្ឈដ្ឋានប៉េឡាសិក ។

# មេរៀនទី៨ ការបំពុលទឹក

ឞ៚*ឞ៚

**សំណួរ១ តើប្រភពនៃការបំពុលទឹកមានប៉ុន្មាន ? អ្វីខ្លះ ?**

ចម្លើយ ប្រភពនៃការបំពុលទឹកមានពីរគឺ ប្រភពបំពុលចំណុច និងប្រភពបំពុលរាយប៉ាយ ។

**សំណួរ២ ចូររៀបរាប់ពីរការបំពុលទឹកក្នុងទឹក ។**

ចម្លើយ ទឹកក្នុងដីត្រូវបានបំពុល ដោយសារទឹកដែលនៅលើផ្ទៃដី ព្រោះទឹកក្នុងដីទទួលបានពីការស្រូបយកពីទឹកលើដី បើកាលណា ទឹក លើដីរងការបំពុលដោយសារធាតុគីមីពុលផ្សេងៗវានឹងនឹង ជ្រាបមកពុលដល់ទឹកក្នុងដី ហើយទឹកក្នុងដីក៏អាចរងការ បំពុលពី សណ្ឋានដីធម្មជាតិរបស់វាផងដែរហើយបើកាលណា ទឹកក្រោម ដីពុលវាពិបាកនឹងសម្អាតណាស់ ។ វាអាចបំពុលពី ប្រភពចំណុច និងប្រភពរាយប៉ាយ ។

**សំណួរ៣ ចូររៀបរាប់ពីការបំពុលមហាសមុទ្រ ដែលកើតឡើងដោយសកម្មភាពមនុស្ស ។**

ចម្លើយ ការបំពុលទឹកសមុទ្រដោយសកម្មភាពមនុស្សមានជាច្រើន ដូចជា ការធ្វេសប្រហែសរបស់នាវាដឹក ប្រេងដែលធ្វើឲ្យមានការកំពប់ប្រេងឆៅចូលក្នុងសមុទ្រ ជាហេតុបណ្ដាលឲ្យកខ្វក់ទឹកសមុទ្រ និងបាត់បង់នូវលំនឹងមានជីវិត ក្នុងសមុទ្រ សំណល់ដ៏ច្រើនលើសលុបនៃប្លាស្ទិចដែល ហូរចូលក្នុងសមុទ្រសម្លាប់ត្រីជាច្រើនដែលបានស៊ីប្លាស្ទិចទាំនោះ ហើយនៅមានសារធាតុបំពុលជាច្រើនទៀត ដូចជា ថ្នាំសម្លាប់សត្វល្អិត DDT ឌីអុកស៊ីន ($C_{12}H_4O_2Cl_4$) និងសារធាតុពុលមានដង់ស៊ីតេខ្ពស់ មាន ដូចជា នីកែល អាសេនិច និង កាត់ម្ញូម ។

**សំណួរ៤ នៅសិសិរផ្លូវក្នុងប្រទេសខ្លះ បាចអំបិលលើផ្លូវដើម្បីឱ្យទឹកកក រលាយ ។ លំហូរទឹកទាំងនោះមានផ្ទុកអំបិល ហើយអាចហូរចូលទៅក្នុង អូរ ស្ទឹង ឬ បឹងដែលនៅជិត ។ តើករណីនេះជាឧទាហរណ៍នៃ ប្រភពបំពុលចំណុច ឬបំពុលរាយបាយ ? ចូរពន្យល់ ។**

**ចម្លើយ:** ក្នុងករណីនេះជាការបំពុលចំណុច ។ ពីព្រោះវាបានបញ្ចេញនូវសារធាតុពុល ដែលហូរចេញពីប្រភពតែមួយគត់ គឺអំបិលដែលហូរចេញពី តាមបណ្ដាឯងផ្លូវនានានៅលើទីក្រុងតែប៉ុណ្ណោះ វាមិនបានលាយជាមួយសារធាតុពុលដទៃទៀតដែលពិបាកនឹងគ្រប់គ្រងទេ គឺមានតែអំបិលលាយជាមួយទឹកកក ។

**សំណួរ៨ តើអ្នកអាចធ្វើដូចម្ដេចខ្លះ ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយការបំពុលទឹក ?**

**ចម្លើយ:** ដើម្បីចូលរួមកាត់បន្ថយការ បំពុលទឹកយើងទាំងអស់គ្នាត្រូវមានវិធានការដូចខាងក្រោម ៖

- ប្រើប្រាស់ទឹកក្នុងការសន្សំសំចៃខ្ពស់
- មិនត្រូវបោះចោលកាកសំណល់ ទាំងឡាយណាដែលបណ្ដាលឲ្យមានការកង្វក់ទឹក
- មិនត្រូវប្រើប្រាស់ថ្នាំសំលាប់ល្អិតនិងជីគីមី ដែលមិនបានត្រួតពិនិត្យត្រឹមត្រូវ
- អប់រំប្រជាជនឲ្យបានយល់ច្បាស់ ពីបញ្ហាបរិស្ថាន និងតម្លៃនៃការខូចខាត និងផលពិបាកតាមរយៈការឃោសនា

គ្រប់រូបភាព បញ្ចូលការអប់រំបរិស្ថានក្នុងកម្មវិធី សិក្សាតាំងពីកម្រិតទាបរហូតដល់កម្រិតខ្ពស់នៃប្រព័ន្ធអប់រំ ។

➢ ក្រសួងពាក់ព័ន្ធ ត្រូវមានវិធានការត្រឹមត្រូវក្នុងការថែរក្សាបរិស្ថាននិងចេះគ្រប់គ្រងនិងតាមដានជាតិពុលទាំងឡាយ ដែលបណ្ដាលឲ្យកង្វក់ទឹក ហើយបណ្ដុះបណ្ដាលមន្ត្រីជំនាញក្នុងការត្រួតពិនិត្យ និងចេះប្រើប្រាស់ឧបករណ៍រកជាតិពុលក្នុងទឹកជាដើម ។

➢ ណែនាំអប់រំដល់ម្ចាស់រោងចក្រ សិប្បកម្ម សហគ្រាស រមណីដ្ឋាន ភោជនីដ្ឋានឲ្យធ្វើអាងសម្អាតកាកសំណល់ទាំងឡាយមុននឹងបង្ហូរចូលក្នុងទឹក ។

➢ បង្កើតក្រុមចុះត្រួតពិនិត្យ និងដាក់ពិន័យចំពោះអ្នកទាំងឡាយណាដែលធ្វើឲ្យមានកង្វក់ទឹក ។

## ១ មេរៀនសង្ខេប

➢ ការបំពុលទឹកគឺជាការបន្ថែមនូវសារធាតុទាំងឡាយណា ដែលធ្វើឲ្យមានផលប៉ះពាល់អវិជ្ជមាន ដល់ទឹកឬសារពាង្គកាយ ដែលរស់នៅក្នុងទឹក ។

➢ អ្នកវិទ្យាសាស្ត្របែងចែកការបំពុលទឹកផ្ទៃលើ ជាពីរគឺ ប្រភពបំពុលចំណុច និងប្រភពបំពុលរាយប៉ាយ ។

➢ សារធាតុបំពុលទឹករួមមាន បណ្តុំនៃសារធាតុគីមី ពួកប៉ាតូស្តែន កត្តាធ្វើឲ្យមានការផ្លាស់ប្តូរលក្ខណៈរូប កត្តាធ្វើឲ្យ សីតុណ្ហភាពទឹកកើនឡើង ការផ្លាស់ប្តូរពណ៌របស់ទឹក ...។ល ។

➢ មហាសមុទ្រគឺជាប្រព័ន្ធដែលអាចសម្អាតដោយខ្លួនឯងបានដោយវាស្រូបយកកាកសំណល់ ដោយមិនបង្កឲ្យមានការ អន្តរាយរយៈពេលវែង ។ សារធាតុបំពុលនៅក្នុងមហាសមុទ្រ រួមមាន ប្រេងឆៅ ប្លាស្ទិច សារធាតុគីមីពុលេការកើនឡើងនៃ សារធាតុចិញ្ចឹម ។

# សំណួរបញ្ចប់ជំពូកទី២

I. ចូរគូសញ្ញា ✓ នៅមុខចម្លើយត្រឹមត្រូវ

១. តើដំណើរការណាមួយដែលមិនមែនជាផ្នែករបស់វដ្តទឹក ?

☐ក. រំហួត ☐ខ. កំណក

☐គ. កណកអាកស ☐ឃ. ការចាក់បង្គរ ។

២. អាងទន្លេធំជាងគេនៅប្រទេសកម្ពុជាគឺ

☐ក. អាងទន្លេមេគង្គ ☐ខ. អាងទន្លេសាប

☐គ. អាងទន្លេសាន ☐ឃ. អាងទន្លេស្រែពក ។

៣.តើចម្លើយមួយណាជាការបំពុលពីប្រភពបំពុលចំណុច ?

☐ក. ដីដែលហូរពីតំបន់កសិដ្ឋាន

☐ខ. ការបង្ហូរទឹកចេញពីផ្លូវទាំងឡាយនៃទីក្រុង

☐គ. បំពុងបង្ហូរសំណល់រាវ

☐ឃ. ការលិចនៃអាងរំងាស់មេរោគ ។

II.*សំណួរ*

១. តើដង្ហើមទឹកត្រូវបានបំពេញបន្ថែមយ៉ាងដូចម្ដេច ?

២. ហេតុអ្វីបានជាល្អាងតែងត្រូវបានគេរកឃើញនៅតំបន់ដែល សម្បូរថ្មកំបោរ ?

៣. តើគេអាចចាត់ទុកទឹកជាធនធានកើតឡើងវិញនិងជាធនធានមិនកើត ឡើងវិញយ៉ាងដូចម្ដេច ? ចូរពន្យល់នូវបំណកស្រាយ និមួយៗ ឱ្យបានច្បាស់លាស់ ។

## III.*លំហាត់*

វិធីក្នុងការវាស់ជម្រៅទឹកក្នុងសមុទ្រត្រូវបានគេគណនាដោយប្រើរូបមន្តងាយខាងក្រោម :

$$D=\frac{1}{2}t\times v$$

D : ជាជម្រៅរបស់ទឹកសមុទ្រ

t : ជារយៈពេលដែលសំលេងឆ្លងកាត់ដើម្បីទៅដល់បាតសមុទ្រហើយ ត្រឡប់មកផ្ទៃខាងលើវិញ ។

v : ជាល្បឿនសំឡេងនៅក្នុងទឹក $(1500m/s)$ ។

គណនាD ចំពោះផ្នែកបីនៃបាតសមុទ្រ បើគេដឹងថាស្នាមប្រេះ

កណ្ដាល មហាសមុទ្រ ($t = 2s$) ជ្រលងមហាសមុទ្រ($t = 14s$) និងផ្ទៃរាបជ្រៅមហាសមុទ្រ ($t = 5.3s$)

# ចម្លើយបញ្ចប់ជំពូកទី២

I. ចូរគូសញ្ញា ✓ នៅមុខចម្លើយត្រឹមត្រូវ

1. តើដំណើរការណាមួយមិនមែនជាផ្នែករបស់វដ្តទឹក

☐ ក. រំហួត ☐ ខ. កំណក

☐ គ. កំណកអាកាស ☑ **ឃ. ការចាក់បង្ហូរ ។**

២. អាងទន្លេធំជាងគេនៅប្រទេសកម្ពុជាគឺ

☐ ក. អាងទន្លេមេគង្គ ☑ **ខ. អាងទន្លេសាប**

☐ គ. អាងទន្លេសាន ☐ ឃ. អាងទន្លេស្រែពក ។

៣.តើចម្លើយមួយណាជាការបំពុលពីប្រភពបំពុលចំណុច ?

☑ **ក. ជីដែលហូរពីតំបន់កសិដ្ឋាន**

☐ ខ. ការបង្ហូរទឹកចេញពីផ្លូវទាំងឡាយនៃទីក្រុង

☐ គ. បំពុងបង្ហូរសំណល់រាវ

☐ឃ. ការលិចនៃអាងរំងាស់មេរោគ ។

## II.សំណួរនិងចម្លើយ

1. ឯង្គើមទឹកត្រូវបានបំពេញបន្ថែម ដោយសារ ភ្លៀងដែល ទើបនឹងធ្លាក់ភ្លាមៗជ្រាបតាមសិលាឆ្អែតទឹក ឬស្រទាប់កំទេច កំណាធ្លូរអាចទឹកចូលនិងស្តុកទឹកបាន ។

2. បានជាគេតែងតែឃើញមាន ល្អាងនៅតំបន់សម្បុថ្មកំបោពីព្រោះមានលក្ខណៈជាសិលាឆ្អែតទឹក និងជាស្រទាប់ដែលមានកម្ទេចកំណាធ្លូរ ដែលមានប្រហោងពេញទៅដោយទឹកនិងជាកន្លែងស្តុកទឹកបង្កើតបានជាល្អាង ។

3. គេអាចចាត់ទុកទឹកជា ធនធានធម្មជាតិកើតឡើងវិញនិងមិនកើតឡើងវិញកាលណា:

➢ ទឹកជាធនធានកើតឡើងវិញ គឺកាលណាវាជាទឹកនៅលើផ្ទៃដី ដែលអាចប្រើប្រាស់ហើយកើតឡើងវិញដោយធម្មជាតិ គឺកើតឡើងតាមវដ្តនៃទឹក ។

➢ ទឹកជាធនធានមិនកើតឡើងវិញ កាលណាទឹកស្ថិតនៅក្រោមទម្រង់ជាទឹកក្រោមដី កាលណាយើងប្រើប្រាស់ដល់

កម្រិតមួយ ដែលលើសពីការជ្រាបចូលពីទឹកនៅ លើដី ជាហេតុធ្វើឲ្យទឹកក្រោមដីបាត់បង់ព្រោះមុននឹង ទឹកលើដី ជ្រាបចូលក្នុងដីក្លាយជានីវ៉ូទឹកក្នុងដីបាន ត្រូវចំណាយពេលយូរបើធៀប នឹងការប្រើប្រាស់ដ៏ច្រើន លើសលុបរបស់មនុស្ស ។

**III. ចម្លើយលំហាត់**

គណនា Dចំពោះផ្នែកបីនៃបាតសមុទ្រ

❖ករណីស្នាមប្រេះកណ្តាលមហាសមុទ្រមាន $t = 2s$

តាមរូបមន្ត $D = \frac{1}{2} t \times v$

ដោយ $t = 2s$ ; $v = 1500 m/s$

$$\Rightarrow D = \frac{1}{2} \times 2 \times 1500$$

$$D = 1500m$$

ដូចនេះ $D = 1500m$ ក្នុងករណី $t = 2$ ។

❖ករណីជ្រលងមហាសមុទ្រមាន $t = 5.3s$

តាមរូបមន្ត $D = \frac{1}{2} t \times v$

ដោយ $t = 14s$; $v = 1500 m/s$

$$\Rightarrow D=\frac{1}{2}\times 14\times 1500 \Rightarrow D=10\ 500m$$

ដូចនេះ $D=10500m$ក្នុងករណី $t=14s$ ។

❖ករណីផ្ទៃរាបជ្រៅមហាសមុទ្រមាន $t=14s$

ដោយ $t=5.3s;\ v=1500m/s$

$$\Rightarrow D=\frac{1}{2}\times 5.3\times 1500 = D=3975m$$

ដូចនេះ $D=3975m$ក្នុងករណី $t=5.3s$

# ជំពូក៣ មណ្ឌលអាកាស អាកាសធាតុ និងធាតុអាកាស

## មេរៀនទី១ លក្ខណៈបរិយាកាស

ೞ೩೦☆೧೦೫

**សំណួរ១ តើបរិយាកាសជាអ្វី ?**

**ចម្លើយ:** បរិកាស ជាបណ្តុំរល្បាយឧស្ម័នព័ទ្ធជុំវិញភពផែនដី ។

**សំណួរ២ តើសមាធាតុសំខាន់ៗនៃបរិយាកាសភពផែនដីមាន អ្វីខ្លះ ? ហើយមាន ប៉ុន្មានភាគរយនៃសមាសធាតុសរុប ?**

**ចម្លើយ:** សមាសធាតុសំខាន់ៗនៃបរិយាកាសផែនដីមាន

- អាសូត មាន78%នៃមាឌបរិកាសសរុប
- អុកស៊ីសែន មាន 21%នៃមាឌបរិកាសសរុប
- ឧស្ម័នផ្សេងៗ មានដូចជា ឧស្ម័នកាបូនិច អាកុង ណេអុង អេល្យូម មេតាន គ្រីបតុង និងអ៊ីដ្រូសែន មានប្រហែល 1% នៃមាឌបរិកាសសរុប ។
- ចំហាយទឹក មានតិចតួចក្នុងបរិយាកាសផែនដី ។

**សំណួរ៣ តើបរិយាកាសភពផែនដីមានប៉ុន្មានស្រទាប់? អ្វីខ្លះ ?**

ចម្លើយ: បរិកាសផែនដីមានស្រទាប់មាន 4ស្រទាប់ ឬ 4 មណ្ឌលគឺ

- មណ្ឌលអាកាសរចល់
- មណ្ឌលអាកាសស្ងប់
- មណ្ឌលកណ្ដាល
- មណ្ឌលកម្ដៅ

**សំណួរ៤ ហេតុដូចម្ដេចបានជាមណ្ឌលកម្ដៅអាចមានសីតុណ្ហភាពខ្ពស់ ប៉ុន្តែមិនមានអារម្មណ៍ថាក្ដៅ ?**

ចម្លើយ បានជាមណ្ឌលកម្ដៅមានសីតុណ្ហភាពខ្ពស់ ប៉ុន្តែមិនមានអារម្មណ៍ថាក្ដៅ ពីព្រោះមណ្ឌលកម្ដៅមានភាគល្អិតតិចតួចដែល ធ្វើចលនាលឿន ហើយសីតុណ្ហភាពកើនឡើងជាមួយនឹងល្បឿន របស់ភាគល្អិតតែដោយភាគល្អិតតិច វាមិនងាយ ប៉ះគ្នាជាហេតុ បណ្ដាលឲ្យមណ្ឌលកម្ដៅមានបន្ទេរថាមពលតិច ទើបមណ្ឌលនេះ មិនមានកម្ដៅក្ដៅ ។

**<u>សំណួរ៥</u> ចូរកំណត់លក្ខណៈមួយៗនៃស្រទាប់បរិយាកាសនីមួយៗ និងពន្យល់អំពី របៀបដែលលក្ខណៈរបស់ស្រទាប់បរិយាកាស**

**ទី៣មួយ៧ជះឥទ្ធិពលមកដល់ជីវិតនៅលើផែនដី ។**

ចម្លើយ:លក្ខណៈរួមមួយនៃស្រទាប់បរិយាកាសនីមួយៗ និង ការជះឥទ្ធិពលមកលើផែនដីមាន ៖

- <u>មណ្ឌលអាកាសរចល់</u> ជាមណ្ឌលស្ថិតនៅជាប់ផែនដី ដែលមានផ្ទុកនូវ ចំហាយទឹក ពពក និងឧស្ម័នផ្សេងៗ ដែលទ្រទ្រង់ជីវិតនៅលើផែនដី ។
- <u>មណ្ឌលអាកាសស្ងប់</u> ជាមណ្ឌលស្ថិតនៅលើបន្ទាប់ពីមណ្ឌលអាកាសរចល់ វាជាកន្លែងដែលផ្ទុកស្រទាប់ អូសូន ដែលជាស្រទាប់ឧស្ម័ន ម៉្យាងដែលស្រូបយកថាមពលព្រះអាទិត្យក្រោមទម្រង់ជាកាំរស្មីស្វាយអ៊ុលត្រា ដែលធ្វើឲ្យបរិយាកាសឡើងក្តៅ ហើយវាការពារជីវិតទាំងឡាយ នៅលើ ផែនដីពីកាំរស្មីស្វាយអ៊ុលត្រា ។
- <u>មណ្ឌលកណ្តាល</u> វានៅពីលើមណ្ឌលអាកាសស្ងប់និងជាស្រទាប់ត្រជាក់ជាងគេបំផុតនៃបរិយាកាស ហើយវាជាស្រទាប់ដែលការពារផ្ទៃផែនដីពីការប៉ះទង្គិចពីអាចម៍ផ្កាយជាច្រើន។

➢ <u>មណ្ឌលកម្ដៅ</u> ជាមណ្ឌលដែលស្ថិតនៅលើគេបង្អស់នៃស្រទាប់បរិយាកាសវាបានការពារផែនដីដោយសារវាបានស្រូបយកកម្ដៅព្រះអាទិត្យមួយភាគធំដែលធ្វើឲ្យ ផែនដីមានកម្ដៅ មួយសមស្រប ។

## ☙ មេរៀនសង្ខេប

- បរិកាសផែនដីកើតឡើងពីឧស្ម័នអាសូតអុស៊ីសែន ឧស្ម័នកាបូនិច ចំហាយទឹក ឧស្ម័នផ្សេងៗនិងភាគល្អិតរឹងនិងធាតុរាវផ្សេងៗទៀត។
- គេចែកបរិយាកាសផែនដីជា 4 ស្រទាប់ឬ 4មណ្ឌលគឺ មណ្ឌលអាកាសរចល់ មណ្ឌលអាកាសស្ងប់ មណ្ឌល កណ្ដាល និងមណ្ឌលកម្ដៅ ។
- សំរាងប៉ូលកើតឡើងនៅក្នុងមណ្ឌលអ៊ីយ៉ុង ។ សំរាងប៉ូលមើលឃើញនៅអឌ្ឍគោលខាងជើងហៅថា សំរាងប៉ូល បូរាលីស ឬពន្លឺខាងជើង ។ ចំណែកសំរាងប៉ូលមើលឃើញនៅ

អឌ្ឍគោលខាងត្បូងហៅថា សំរាងប៉ូលអូស្ត្រាលី ឬពន្លឺខាងត្បូង ។

# មេរៀនទី២ សម្ពាធបរិយាកាស

ႏၵ★ႏၵ

**សំណួរ១ តើអ្វីជាសម្ពាធបរិយាកាស ?**

ចម្លើយ: សម្ពាធបរិយាកាស ជាបរិមាណនៃកម្លាំងខ្យល់ដែលសង្កត់លើតំបន់មួយនៃផ្ទៃដី ។

**សំណួរ២ តើហេតុអ្វីបានជាសម្ពាធបរិយាកាសថយចុះ នៅពេលរយៈកម្ពស់កើន ឡើង ?**

ចម្លើយ: បានជាសម្ពាធថយចុះ នៅពេលរយៈកម្ពស់កើនឡើង ពីព្រោះ បរិយាកាសផែនដីស្ថិតនៅព័ន្ធជុំវិញដោយសារទំនាញ ហើយទំនាញបានទាញម៉ូលេគុលឧស្ម័នមកលើផែនដីដោយសារទំងន់សង្កត់ ទៅលើម៉ូលេគុលទាំងនោះបណ្តាលឲ្យខ្យល់ រុញផ្ទប់មកលើផែនដី ហើយបើកាលណា

រយៈកម្ពស់កាន់តែ ខ្ពស់ម៉ូលេគុលឧស្ម័នដែលរុញមកលើ យើងកាន់តែតិចទៅៗ និង ស្ថិតនៅឆ្ងាយពីគ្នាជាហេតុ បណ្តាល ឲ្យមានសម្ពាធកាន់តែ ខ្សោយ ។

**សំណួរ៣ តើម៉ាសមាឌនៃខ្យល់មានទំនាក់ទំនងយ៉ាងដូម្តេច ជាមួយនឹងសម្ពាធបរិយាកាស ?**

**ចម្លើយ:** ម៉ាសមាឌនៃខ្យល់ មានទំនាក់ទំនងនិងបរិយាកាស ដោយវាសមាមាត្រនឹងគ្នាគឺវាថយចុះនៅរយៈកម្ពស់ខ្ពស់ដូច គ្នាកើនឡើង នៅរយៈកម្ពស់ទាបគៀកនឹងផែនដីដូចគ្នា ។

**<u>សំណួរ៤</u> រយៈកម្ពស់ជះឥទ្ធិពលដល់សម្ពាធបរិយាកាស ។ ចូរពន្យល់ដោយលើក ឧទាហរណ៍មកបញ្ជាក់ ។**

**ចម្លើយ:** រយៈកម្ពស់ខ្ពស់បានជះឥទ្ធិពលដល់ សម្ពាធបរិយាកាសដោយសម្ពាធបរិយាកាសកើនឡើងជាមួយរយៈកម្ពស់ កាន់តែ ខ្ពស់ និងថយចុះជាមួយរយៈកម្ពស់កាន់តែទាប ។ ឧទាហរណ៍ ពេលយើងឡើងលើភ្នំកាន់តែខ្ពស់យើង នឹងដកដង្ហើមកាន់តែ ញាប់ នេះបណ្តាលមកពីម៉ូលេគុលខ្យល់នៅ

លើកំពូលភ្នំមានតិចធ្វើឲ្យខ្យល់អុកស៊ីសែន ។ បើកាលណាម៉ូលេគុលខ្យល់ថយចុះ នោះសម្ពាធបរិកាសក៏ថយចុះដែរ នេះបញ្ជាក់ថា រយៈកម្ពស់ ខ្ពស់ បានជះឥទ្ធិពលដល់ការកើន ឬចុះនៃសម្ពាធបរិយាកាស ។

**<u>សំណួរ៥</u> គេកត់ត្រាទិន្នន័យសម្ពាធ បរិយាកាសនៅតំបន់ មួយ ដោយបារ៉ូម៉ែត្រ បារត ស្មើនឹង 7.61.1mm បារត ។ ចូរគណនាទៅជាហិច តូប៉ាស្កាល់ ។**

**ចម្លើយ:** គណនាប៉ារ៉ាម៉ែតទៅជា ហិចតូប៉ាស្កាល់

ដោយ $760mm = 1013.2hPa$

$$\Rightarrow 761.1mm \text{ បារត } = \frac{1013.2 \times 761.1}{760} = 1014.46$$

ដូចនេះ $761.1mm$ បារតស្មើនឹង $1014.46hPa$ ។

## ៤ មេរៀនសង្ខេប

➢ សម្ពាធបរិយាកាស ជាបរិមាណនៃកម្លាំងខ្យល់ដែល

សង្កត់លើតំបន់មួយនៃផ្ទៃដី ។ ខ្យល់ដែលព័ទ្ធជុំវិញផែនដីមានទំងន់ប្រហែល $5136\times10^{8} Kg$

➢ សម្ពាធអាកាសអាចគណនាបានតាមរូបមន្ត

សម្ពាធ = កម្លាំង ÷ ផ្ទៃក្រលា

➢ បរិយាកាសផែនដីស្ថិតនៅព័ន្ធជុំវិញដោយសារទំនាញ ។

➢ បារ៉ូម៉ែត្រ គឺជាឧបករណ៍ដែលប្រើសំរាប់វាស់សម្ពាធខ្យល់ ។

➢ ខ្នាតសម្ពាធគឺ មីលីបា (mb) ឬហិចតូប៉ាស្កាល់ (hPa) ។

## មេរៀនទី៣ . ធាតុអាកាស និងអាកាសធាតុ

**សំណួរ១ តើធាតុរបស់ធាតុអាកាសមានអ្វីខ្លះ ?**

**ចម្លើយ:** ធាតុរបស់ធាតុអាកាសមាន៖

សីតុណ្ហភាពខ្យល់ សម្ពាធខ្យល់ សំណើម ពពក

កំណាកអាកាស ខ្យល់បក់

**សំណួរ២ ចូរធ្វើការប្រៀបធៀបធាតុអាកាស និងអាកាសធាតុ ។**

**ចម្លើយ:** ប្រៀបធៀបធាតុអាកាស និងអាកាសធាតុ៖

ធាតុអាកាស គឺជាលក្ខខណ្ឌបរិយាកាស ទីកន្លែង និង ពេលវេលាមួយជាក់លាក់ហើយវាអាចប្រែប្រួល ដូចជាពេលខ្លះមានភ្លៀង ពេលខ្លះមានខ្យល់...។

អាកាសធាតុ គឺជាតំណាងឲ្យការប្រមូលផ្តុំ ព្រឹត្តិការណ៍ប្រចាំថ្ងៃរីតាមរដូវក្នុងកំឡុងរយៈពេលវែងមួយ។

សំណួរ៤ ហេតុអ្វីបានជានៅក្នុងទសវត្សរ៍ថ្មីៗនេះ អ្នកវិទ្យា

សាស្ត្រជាច្រើន មានការ ព្រួយបារម្ភចំពោះការកើនឡើង នូវឧស្ម័នផ្ទះកញ្ចក់ ?

ចម្លើយ: បានជានៅក្នុងទសវត្សរ៍ថ្មីៗនេះ អ្នកវិទ្យាសាស្ត្រជាច្រើនបានព្រួយបារម្ភចំពោះ ការកើនឡើងនៅឧស្ម័នផ្ទះកញ្ចក់ពីព្រោះ ឧស្ម័នផ្ទះកញ្ចក់បណ្តាលឲ្យកើតឡើងនូវ កម្តៅនៅលើផែនដីយ៉ាងឆាប់រហ័សបណ្តាលឲ្យប៉ះដល់ជីវិតនៅលើផែនដី។

---

## មេរៀនសង្ខេប

**ធាតុអាកាស** គឺជាលក្ខខណ្ឌបរិយាកាសនៅទីកន្លែងនិងពេលវេលាណាមួយដែលជាក់លាក់ ។ អាកាសធាតុគឺជាតំណាងឱ្យការប្រមូលផ្តុំព្រឹត្តិការណ៍ធាតុអាកាសប្រចាំថ្ងៃឬតាមរដូវក្នុងអំឡុងរយៈ ពេលវែងមួយ ។ផែនដីទទួលថាមពលពីព្រះអាទិត្យដោយវិធីបីយ៉ាង គឺ រំភាយរស្មី ការចម្លងកម្តៅ និងចលនាវិលវល់ ។ ដំណើរកម្តៅរបស់ផែនដីដែលឧស្ម័ននៅក្នុងបរិយាកាសឃាំងជាប់

ជាថាមពល កម្តៅហៅថាផលផ្ទះកញ្ចក់ឧស្ម័នទាំងឡាយ ចាប់យកថាមពល កម្តៅ ហៅថា ឧស្ម័នផ្ទះកញ្ចក់ ។

## មេរៀនទី៤ សម្ពាធខ្ពស់ និងសម្ពាធទាបតាមរដូវ

**សំណួរ១ តើអ្វីជាប្រព័ន្ធសម្ពាធ ?**

**ចម្លើយ:** ប្រព័ន្ធសម្ពាធ គឺជាតំបន់បរិយាកាសផែនដីនិងជាកន្លែង ដែលមានសម្ពាធខ្យល់ទាបឬ ខ្ពស់។

**សំណួរ២ តើអ្វីជាតំបន់ជំនួបចន្លោះត្រូពិច (Inter-Tropical Convergence Zone- ITCZ)?**

**ចម្លើយ:** តំបន់ជំនួបចន្លោះត្រូពិច( Inter-tropical Covergence Zone-ITCZ) គឺជាក្រវាត់សម្ពាធខ្សោយមួយដែលព័ទ្ធ ជុំវិញផែនដី នៅជិតអេក្វាទ័រ។

**<u>សំណួរ៤</u> តាមរយៈរូបទី ៥ ចូរបកស្រាយ ពីមូលហេតុ ដែលនាំឱ្យទីក្រុងឡូសអង់ ជឺលេស និងទីក្រុងអាត្លង់តា មាន កំណក**

**អាកាសមធ្យមប្រចាំឆ្នាំខុសគ្នា ។**

<u>ចម្លើយ:</u>មូលហេតុដែលបណ្ដាលឲ្យទីក្រុងឡូសអង់ជីឡេស និងទីក្រុងអាត្លង់តាមានកំណាកអាកាស មធ្យមប្រចាំឆ្នាំខុសគ្នាគឺបណ្ដាលមកពីទីក្រុងទាំងពីនេះ ស្ថិតនៅប្រព័ន្ធសម្ពាធខុសគ្នាដែល ៖

- ទីក្រុងឡូសអង់ជីឡេស ស្ថិតនៅក្នុងប្រព័ន្ធសម្ពាធខ្ពស់ប៉ាស៊ីភិច ដែលមានអាកាសធាតុក្ដៅហើយ ស្ងួតដែលបណ្ដាលឲ្យមានកំណាកអាកាសមធ្យមប្រចាំឆ្នាំតិច ។
- ទីក្រុងអាត្លង់តា ស្ថិតនៅក្នុងប្រព័ន្ធសម្ពាធខ្ពស់ប៊ែម៉ុយដា(Bermuda) ដែលមានខ្យល់បក់នាំមកជាមួយនៅសំណើមស្អុះឡើងជាកំណាកអាកាស ជាហេតុបណ្ដាលឲ្យទីក្រុងនេះមានកំណាកអាកាសប្រចាំឆ្នាំខ្ពស់ ។

## មេរៀនសង្ខេប

- ប្រព័ន្ធសម្ពាធ គឺជាតំបន់បរិយាកាសផែនដី ជាកន្លែងដែលមានសម្ពាធ ខ្យល់ទាប ឬខ្ពស់ ។
- តំបន់ជំនួបចន្លោះត្រូពិច ( Inter-tropical Covergence Zone-ITCZ) ជា ក្រវាត់សម្ពាធខ្សោយមួយ ដែលព័ទ្ធជុំវិញផែនដីនៅជិតអេក្វាទ័រ ។
- ប្រព័ន្ធសម្ពាធពាក់កណ្ដាលអចិន្ត្រៃយ៍បួននៅអឌ្ឍគោលខាងជើង នៅ ខែមករាស្ថិតនៅចន្លោះរយៈទទឹង ២៥ ដឺក្រេខាងជើង គឺប្រព័ន្ធសម្ពាធ ខ្ពស់ប៊ែរមុយដា ប្រព័ន្ធសម្ពាធខ្ពស់ប៉ាស៊ីភិច ប្រព័ន្ធសម្ពាធទាបអាយស៏ លែន និងប្រព័ន្ធទាប អាលូស៊ាន ។
- ប្រព័ន្ធសម្ពាធផ្សេងៗទៀត មានប្រព័ន្ធសម្ពាធខ្ពស់ស៊ីបេរី ប្រព័ន្ធសម្ពាធ ខ្ពស់កាណាដា និងប្រព័ន្ធសម្ពាធទាបក្ដៅ

<u>ឧទាហរណ៍</u> : ( ប្រព័ន្ធសម្ពាធ ទាបមូសុង ) ។

# មេរៀនទី៥ ខ្យល់បក់

ឲ☆ឲ

**សំណួរ១ ហេតុអ្វីបានជាមានខ្យល់បក់ ?**

**ចម្លើយ:** បានជាមានខ្យល់បក់ គឺដោយសារសម្ពាធខ្យល់ពីរខុសគ្នាដែលបណ្តាលមកពីរកំដៅនៅលើផែនដីមិនស្មើគ្នា។

**សំណួរ២ តើឥទ្ធិពលកូរីយ៉ូលីស ជះឥទ្ធិពលដូចម្តេចខ្លះចំពោះចលនាខ្យល់បក់ ?**

**ចម្លើយ:** ឥទ្ធិពលកូរីយ៉ូលីស(Coriolis Effect) ជះឥទ្ធិពលដល់ចលនាខ្យល់បក់ ដោយវាធ្វើឲ្យខ្យល់និងទឹកសមុទ្រ ធ្វើចលនាកោង បើគ្មានវា ខ្យល់នឹងធ្វើចលនាតាមទិសត្រង់ពីប៉ូលទៅអេក្វាទ័រ។

**សំណួរ៣ ចូរប្រៀបធៀបខ្យល់ប្រចាំតំបន់និងខ្យល់ប្រចាំទី ។**

**ចម្លើយ:** ប្រៀបធៀបខ្យល់បក់ប្រចាំតំបន់និង ខ្យល់ប្រចាំទី៖

✓ខ្យល់បក់ប្រចាំតំបន់ ជាផ្នែកមួយនៃគំរូចរន្តខ្យល់ ដែលធ្វើចលនាកាត់ផែនដី វាកើតពីកម្តៅមិនស្មើគ្នានៃផែន ដី

ខ្យល់បក់ប្រចាំតំបន់រួមមាន ខ្យល់ជំនួញ ខ្យល់បក់ពីទិស ខាងលិច និងខ្យល់ប៉ូលបក់ពីទិសខាងកើត ។

✓ ខ្យល់បក់ប្រចាំទីជាខ្យល់ទទួលឥទ្ធិពលពីភូមិសាស្ត្រ តំបន់មួយនៃតំបន់ ដែលវាបានឆ្លងកាត់មានដូចជា មាត់សមុទ្រ ឬភ្នំ ដែលមានសីតុណ្ហភាពមិនស្មើគ្នា ។

**សំណួរ៨ ចូររៀបរាប់ដោយសង្ខេបពីក្រវាត់ខ្យល់បក់ប្រចាំតំបន់ទាំងបីនិងទី តាំងដែលវាស្ថិតនៅ ។**

**ចម្លើយ:** ក្រវាត់ខ្យល់តាមតំបន់ទាំងបី និងទីតាំងដែលវាស្ថិតនៅមាន៖

✓ ខ្យល់ជំនួញ ជាខ្យល់មានរយៈទទឹង 30° ស្ថិតនៅអេក្វាទ័រនៃអឌ្ឍគោលទាំងពីរ ។

✓ ខ្យល់បក់ពីទិសខាងលិច ជាក្រវាត់ខ្យល់ដែលស្ថិតនៅលើអឌ្ឍគោលទាំងពីរក្នុងចន្លោះរយៈទទឹងពី30°ទៅ60° វាបក់ពីទិសខាងលិចបក់ឆ្ពោះទៅកាន់ប៉ូលក្នុង ទិសដៅផ្ទុយពី ខ្យល់ជំនួញ ។

✓ ខ្យល់ប៉ូលបក់ពីទិសខាងកើត ជាក្រវាត់ខ្យល់ដែល លាត

សន្ទីងចាប់ពីប៉ូលមករយៈទទឹង60°នៃអឌ្ឍគោលទាំងពីរ ។

**សំណួរ៨ តើជំនោរសមុទ្រនិងជំនោរទ្វីបកើតឡើងដូចម្តេច ?**

**ចម្លើយ:** ជំនោរសមុទ្រ និងជំនោរទ្វីបកើតឡើងដូចដោយសារ

**ជំនោរសមុទ្រ** កើតឡើងពេលផ្ទៃដីមានកម្តៅបង្កើត បាន ជាខ្យល់ក្តៅស្រាលហោះឡើងលើ បណ្តាលឲ្យមាន សម្ពាធខ្សោយជាងខ្យល់សមុទ្រ ដែលត្រជាក់និង មាន សម្ពាធខ្លាំង ធ្វើឲ្យខ្យល់ធ្វើចលនាពីសមុទ្រទៅកាន់ទ្វីប បង្កើតបានជាជំសមុទ្រ ។

**ជំនោរទ្វីប** កើតឡើងពីខ្យល់នៅទ្វីបពេលយប់ចុះត្រ ជាក់ ជាងខ្យល់នៅក្នុងមហាសមុទ្រជាហេតុបណ្តាលឲ្យមាន សម្ពាធខ្លាំងនៅលើទ្វីប និងសម្ពាធខ្សោយនៅលើមហា សមុទ្រធ្វើឲ្យមានខ្យល់បក់ពីទ្វីបចុះមកមហាសមុទ្រវិញ បង្កើត បានជាជំនោរទ្វីប ។

**ខ្យល់បក់** បណ្តាលមកពីកម្តៅ មិនស្មើគ្នានៅលើផែនដី។ បម្រែបម្រួលកម្តៅនេះបង្កើតឱ្យមានក្រវាត់សម្ពាធនៅរៀង រាល់ប្រហែល30° ម្តងខ្យល់និងទឹកធ្វើចលនាវេរ( កោង) ដោយ

សារឥទ្ធិពល កូរីយ៉ូលីស ។

**ខ្យល់បក់នៅលើផែនដីមានពីរប្រភេទ** គឺខ្យល់បក់ប្រចាំទីនិង ខ្យល់បក់ ប្រចាំតំបន់ ។

**មានតំបន់ស្ងប់ខ្យល់ពីរ**ស្ថិតនៅជុំវិញអេក្វាទ័រ និងរយៈ ទទឹង30° ។ ចរន្តសេតស្ទ្រីមមិនត្រូវបានគេចាត់ទុកជាខ្យល់ បក់ប្រចាំតំបន់ទេ ព្រោះវាមានទិសដៅពុំទៀងទាត់ ។

# មេរៀនទី៦ ខ្យល់ម៉ូសុង និងឥទ្ធិពលរបស់វា

## សំណួរ១

ក. ចូរប្រើតារាងព័ត៌មានធាតុអាកាសខេត្តសៀមរាបដើម្បីគូរក្រាប សីតុណ្ហភាពនិងកំពស់ទឹកភ្លៀង

| ខែ | មក | កុ | មី | មេ | ឧ | មិថុ | កក | សី | កញ្ញ | តុ | វិច្ឆ | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| សីតុ | 25.9 | 27. | 30.3 | 30.3 | 30.3 | 29.1 | 28.7 | 28.7 | 28.3 | 27.6 | 26.5 | 25.6 |
| ភ្លៀង | 0.7 | 3.5 | 28.0 | 16.2 | 175. | 221. | 236. | 151. | 276.1 | 248. | 81.7 | 10.1 |

ខ. ចូរប្រៀបធៀបក្រាបធាតុអាកាសខេត្តសៀមរាបជាមួយនឹង ក្រាបធាតុអាកាសភ្នំពេញ ។

## ចម្លើយ

ក. គូសក្រាបតាងសីតុណ្ហភាពនិងកម្ពស់ទឹកភ្លៀង

*※ក្រាបតាងសីតុណ្ហភាព*




## ❋ ក្រាបតាងកម្ពស់ទឹកភ្លៀង



ខ.ប្រៀបធៀបក្រាបតាងសីតុណ្ហភាពនិងកម្ពស់ទឹកភ្លៀងរវាងទីក្រុងភ្នំពេញនិងខេត្តសៀមរាប

| ❖ទីក្រុងភ្នំពេញ | ❖ខេត្តសៀមរាប |
|---|---|
| ➢ *កម្ពស់ទឹកភ្លៀង*<br>❖អតិបរមា 318mm<br>❖អប្បរមា 11.5mm<br>❖មធ្យមប្រចាំឆ្នាំ136.13mm | ➢ *កម្ពស់ទឹកភ្លៀង*<br>❖អតិបរមា 276.1mm<br>❖អប្បរមា 0.7mm<br>❖មធ្យមប្រចាំឆ្នាំ124.6mm |
| ➢ *សីតុណ្ហភាព* | ➢ *សីតុណ្ហភាព* |
| ❖អតិបរមា 34.9°C<br>❖អប្បរមា 21.7 °C | ❖អតិបរមា 30.3°C<br>❖អប្បរមា 25.6°C<br>❖មធ្យមប្រចាំឆ្នាំ28.19°C |

**<u>សន្និដ្ឋាន</u>** : តាមតារាងគេសង្កេតឃើញថា ក្រាបតាងអាកាសធាតុរវាងក្រុងភ្នំពេញ និងខេត្តសៀមរាប មានលក្ខណៈផ្ទុយគ្នា ព្រោះថាក្រាបតាងអាកាសធាតុនៅទីក្រុងភ្នំពេញមានទិន្នន័យ ខ្ពស់ ជាងខេត្តសៀមរាបដែលបញ្ជាក់

សីតុណ្ហភាព និងកម្ពស់ទឹកភ្លៀងនៅទីក្រុងភ្នំពេញខ្ពស់ជាងខេត្តសៀមរាបគ្រប់រដូវ ។

**សំណួរ២ រៀបរាប់ពីលក្ខណៈអាកាសធាតុនៅប្រទេសកម្ពុជា ។**

**ចម្លើយ:**លក្ខណៈអាកាសធាតុប្រទេសកម្ពុជា ជាកាសធាតុត្រូពិចមូសុងក្តៅហើយសើម ។ គេឃើញមានរដូវពីរសំខាន់ ៗគឺ

រដូវប្រាំង: ក្តៅហើយសើម ហើយវាចែកជាពីរគឺ ខែវិច្ឆិកាដល់ខែមករាជារដូវរំហើយត្រជាក់ស្រួល និងពីខែកុម្ភៈដល់ខែមេសារដូវក្តៅពិបាករស់នៅ។

រដូវវស្សា: សើមហើយមានភ្លៀងច្រើន វាចាប់ផ្តើមពីខែឧសភាដល់ខែតុលា ។

**សំណួរ៣ ប្រទេសកម្ពុជាទទួលឥទ្ធិពលខ្យល់មូសុងដែល បង្កើតរដូវពីរច្បាស់លាស់ ។ ចូរពណ៌នាពីរដូវសំខាន់ៗនៅប្រទេសកម្ពុជា ។**

**ចម្លើយ** ប្រទេសកម្ពុជា ទទួលឥទ្ធិពលខ្យល់ខ្យល់មូសុងដែលបង្កើតរដូវពីរច្បាស់លាស់គឺ

រដូវប្រាំង គិតបក់ពីខែវិច្ឆិកាដល់ខែមេសា ខ្យល់មូសុង

បក់ចេញបីទិសទៅទិសនិរតីចេញពីប្រភពស៊ីបេរី ដែល ជាតំបន់កណ្តាលទ្វីប និងជាតំបន់មានសម្ពាធខ្លាំងខ្យល់នេះគ្មាននាំភ្លៀងមកទេ តែមានខែខ្លះមានភ្លៀងធ្លាក់បន្តិច បន្តួចដូចជាខែកុម្ភៈជាដើម ។ គេចែករដូវប្រាំងជារដូវធំៗ ពីរគឺ៖

- ខែវិច្ឆិកាដល់ខែមករាជា រដូវរំហើយត្រជាក់ស្រួល ពីខែកុម្ភៈដល់ខែមេសារដូវក្តៅពិបាករស់នៅ។

**រដូវវស្សា** ពីខែឧសភាទៅខែតុលា ខ្យល់មូសុងបក់ពីទិសនិរតីនិងត្បូងជាខ្យល់ក្តៅហើយសើមបក់ចេញពីមហាសមុទ្រឥណ្ឌាជាតំបន់មានសម្ពាធខ្លាំង ទៅស៊ីបេរីកណ្តាលទ្វីបវិញវាបាននាំមកជាមួយនូវភ្លៀងជាច្រើនបង្កើតបានជារដូវភ្លៀងហើយសើម ។

# មេរៀនទី៧ តំបន់អាកាសធាតុ

៣៤☆៣៦

**សំណួរ១ គេចែកតំបន់អាកាសធាតុជាប៉ុន្មានតំបន់? អ្វីខ្លះ ? ចូររៀបរាប់ លក្ខណៈអាកាសធាតុនៃតំបន់ទាំងនោះ ។**

**ចម្លើយ:** គេចែកតំបន់អាកាសធាតុជាបីសំខាន់ៗគឺ

តំបន់អាកាសធាតុត្រូពិច មានសីតុណ្ហភាពនិងសំណើម ខ្ពស់ជាធម្មតាបរមាណទឹកភ្លៀងមានច្រើនស្មើតែពេញ មួយឆ្នាំ តំបន់នេះមានខ្យល់បក់ពីខាងលិចឆ្ពោះទៅឆ្នេ សមុទ្រ។

តំបន់អាកាសធាតុត្រជាក់បង្គួរ តំបន់នេះ សីតុណ្ហភាពជាកក្តាសំខាន់សម្រាប់កំណត់រដូវឲ្យខុសគ្នា និងដាច់ពី គ្នាគឺមិនមែនដូចតំបន់ត្រូពិចទេសីតុណ្ហភាពតំបន់នេះទទួលឥទ្ធិពលពីម៉ាសខ្យល់ប៉ូលផងនិងត្រូពិចផង ។ អាកាសធាតុត្រជាក់បង្គួរចែកជាពីរប្រភេទគឺ អាកាសធាតុត្រជាក់បង្គួរសមុទ្រនិងទ្វីប ។

តំបន់អាកាសធាតុប៉ូលៈ តំបន់អាកាសធាតុមានសីតុណ្ហភាព

ត្រជាក់ជាងគេបំផុត សីតុណ្ហភាពតំបន់ ស្ថិតនៅក្រោម $0°C$ ជានិច្ចទោះជារដូវក្តៅក៏ដោយក៏ សីតុណ្ហភាពមធ្យមមិនលើសពី $10°C$ ដែរ ហើយតំបន់នេះមានភ្លៀងធ្លាក់តិចតួចណាស់រដូវទឹកកកជារាត្រីប៉ូលដែលរដូវនេះមានយប់6ខែ ។

**សំណួរ២ ចូរគូសក្រាភិចតាងកម្ពស់ទឹកភ្លៀងនិងសីតុណ្ហភាពនៃទីក្រុងស៊ីដនី ( អូស្ត្រាលី) និងទីក្រុងតូក្យូ ( ជប៉ុន) ដោយប្រើតារាងខាងក្រោម :**

### ស៊ីដនី ប្រទេសអូស្ត្រាលី

| ខែ | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| សីតុ | 22.3 | 22.4 | 21.5 | 18.4 | 15.6 | 13.4 | 12.4 | 13.4 | 15.3 | 17.7 | 19.6 | 21.5 |
| ភ្លៀង | 15.1 | 112.5 | 147.5 | 12.5 | 88.0 | 128.2 | 54.3 | 89.9 | 360.6 | 78.5 | 101.1 | 80.7 |

### តូក្យូ ប្រទេសជប៉ុន

| ខែ | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| សីតុ | 4.7 | 5.4 | 8.4 | 13.9 | 18.4 | 21.5 | 25.2 | 26.7 | 22.9 | 17.3 | 12.3 | 7.4 |
| ភ្លៀង | 45.1 | 60.4 | 99.5 | 125.0 | 138.0 | 185.2 | 126.1 | 147.5 | 179.8 | 164.1 | 89.1 | 45.7 |

ក. វិភាគទិន្នន័យក្រាភិចនៃទីក្រុងទាំងពីរ ។

ខ. ប្រៀបធៀបទិន្នន័យក្រាភិចនៃទីក្រុងទាំងពីរ ។

គ. សន្និដ្ឋានថា តើទីក្រុងទាំងពីរស្ថិតនៅក្នុងតំបន់អាកាសធាតុមួយណា ?

ចម្លើយ:

ក្រាបតាងកម្ពស់ទឹកភ្លៀងនិងសីតុណ្ហភាពនៅទីក្រុងតូក្យូ (ប្រទេសជប៉ុន) និងទីក្រុងស៊ីដនី (អូស្ត្រាលី)

❖ទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី

✵ក្រាបតាងសីតុណ្ហភាព




✵ក្រាបតាងកម្ពស់ទឹកភ្លៀង




❖ទីក្រុងតូក្យូ ប្រទេសជប៉ុន

✵ក្រាបតាងសីតុណ្ហភាព




✵ក្រាបតាងកម្ពស់ទឹកភ្លៀង



ក. តាមក្រាភិចយើងសង្កេតឃើញថា ទីក្រុងទាំងពីមាន

❖ តាមក្រាភិចទីក្រុងស៊ីដនី មានភ្លៀងធ្លាក់ពេញមួយឆ្នាំ ហើយមានកម្ពស់ទឹកភ្លៀងអតិបរមា 360.2mm និងអប្បរ មា 12.5mm សីតុណ្ហភាពអតិបរមាមាន $22.4^{0}C$ និង អប្បរមាមាន $12.4^{o}C$ ។ លក្ខខណ្ឌទាំងនេះបញ្ជាក់ថា ទីក្រុង មានសីតុណ្ហភាពប្រចាំឆ្នាំខ្ពស់ រដូវត្រជាក់ខ្លាំង មិនសូវមានទេ ចន្លោះកម្តៅរវាងរដូវក្តៅនិងត្រជាក់មាន កម្រិតទាបហើយរដូវ ទាំងពីរជារដូវត្រជាក់ល្មម និងមានភ្លៀងធ្លាក់ច្រើននៅរដូវ ត្រជាក់។

❖ ទីក្រុងតូក្យូ មានភ្លៀងធ្លាក់ពេញមួយឆ្នាំហើយមាន កម្ពស់ទឹកភ្លៀងអតិបរមា 185.2mm និងអប្បរមាមាន 45.1mm សីតុណ្ហភាពអតិបរមាមាន $26.7^{0}C$ និងអប្បរមា មាន $4.7^{o}C$ ។ លក្ខខណ្ឌទាំងនេះបញ្ជាក់ថា ទីក្រុងមានចន្លោះ កម្តៅប្រចាំឆ្នាំ មានកម្រិតខ្ពស់រដូវក្តៅ ក្តៅខ្លាំង(ខែសីហា) រដូវត្រជាក់ ត្រជាក់ខ្លាំង (ខែមករា) និងមានភ្លៀងធ្លាក់ច្រើន នៅរដូវក្តៅ ។

ខ.តាមក្រាបគេអាចប្រៀបធៀបរវាងទិន្នន័យទីក្រុងស៊ីដនី និងទីក្រុងតូក្យូដូចខាងក្រោម

| ❖ទីក្រុងស៊ីដនី | ❖ទីក្រុងតូក្យូ |
|---|---|
| ❖កម្ពស់ទឹកភ្លៀង | ❖កម្ពស់ទឹកភ្លៀង |
| ❖អតិបរមា 360.2mm | ❖អតិបរមា 185.2mm |
| ❖អប្បរមា 12.5mm | ❖អប្បរមា 45.1mm |
| ❖មធ្យមប្រចាំឆ្នាំ105.7mm | ❖មធ្យមប្រចាំឆ្នាំ117.12mm |
| ❖សីតុណ្ហភាព | ❖សីតុណ្ហភាព |
| ❖អតិបរមា 22.4°C | ❖អតិបរមា 26.7°C |
| ❖អប្បរមា 12.4 °C | ❖អប្បរមា 4.7°C |
| ❖មធ្យមប្រចាំឆ្នាំ17.79°C | ❖មធ្យមប្រចាំឆ្នាំ15.34°C |

**<u>សន្និដ្ឋាន</u>** : តាមតារាងគេសង្កេតឃើញថា ក្រាបតាងអាកាសធាតុរវាងទីក្រុងស៊ីដនី និងទីក្រុងតូក្យូ មានលក្ខណៈផ្ទុយគ្នាមួយចំនួនព្រោះថាក្រាបតាងសីតុណ្ហភាពនៅទីក្រុងស៊ីដនីមានទិន្នន័យមធ្យមប្រចាំឆ្នាំខ្ពស់ជាងទីក្រុងស៊ីដនីកម្ពស់ទឹកភ្លៀង នៅទីក្រុងតូក្យូ មានទិន្នន័យមធ្យមប្រចាំឆ្នាំខ្ពស់ជាង

ទីក្រុងស៊ីដនី ដែលបញ្ជាក់អំពី៖

**ទីក្រុងស៊ីដនី** មានទឹកភ្លៀងធ្លាក់ពេញមួយឆ្នាំភ្លៀងធ្លាក់ច្រើននៅរដូវត្រជាក់ និងធ្លាក់ច្រើនជាងគេនៅខែកញ្ញា សីតុណ្ហភាពមានកម្រិតខ្ពស់ហើយរដូវមិនសូវមានរដូវត្រជាក់ខ្លាំងទេវា គឺជារដូវត្រជាក់ស្រួលរស់នៅ ។

**ទីក្រុងតូក្យូ** មានភ្លៀងធ្លាក់មិនសូវជាច្រើនប៉ុន្មានទេ តែវាធ្លាក់ច្រើននៅរដូវក្តៅ គឺចន្លោះពី ខែមេសាដល់ខែតុលា ហើយ អាកាសធាតុនៅរដូវត្រជាក់ ត្រជាក់ខ្លាំងនិងនៅរដូវក្តៅ មានធាតុ អាកាសក្តៅខ្លាំង ។

៤ តាមការពិនិត្យនេះយើងអាចសន្និដ្ឋានបានថា ទីក្រុងតូក្យូមានសីតុណ្ហភាពក្តៅ និងត្រជាក់ជាងទីក្រុងស៊ីដនី ទីក្រុងស៊ីដនីមានភ្លៀងធ្លាក់ច្រើនជាងទីក្រុងតូក្យូ ហើយទីក្រុងតូក្យូមានភ្លៀងធ្លាក់នៅរដូវក្តៅច្រើនខុសពីទីក្រុងស៊ីដនីមានភ្លៀងធ្លាក់ច្រើននៅរដូវត្រជាក់ ។

**គ. តាមក្រាបយើងអាចសន្និដ្ឋានបានថា**

**ទីក្រុងស៊ីដនី** ស្ថិតនៅក្នុងតំបន់អាកាសធាតុត្រជាក់បង្គួរ

សមុទ្រ

ទីក្រុងតូក្យូ ស្ថិតនៅក្នុងតំបន់អាកាសធាតុត្រជាក់បង្គួរទ្វីប ។

## មេរៀនសង្ខេប

- នៅលើផែនដីយើងមានតំបន់អាកាសធាតុធំៗបីគឺ តំបន់អាកាសធាតុ **ត្រូពិច ត្រជាក់បង្គួរ និងប៉ូល** ។
- អាកាសធាតុនៅគ្រប់តំបន់លើពិភពលោកត្រូវបានកំណត់ដោយកត្តាសំខាន់ពីរជាមូលដ្ឋានគឺសីតុណ្ហភាពនិងកំណកអាកាស ។ តាមរយៈការគូក្រាភិច តាងកម្ពស់ទឹកភ្លៀងនិង សីតុណ្ហភាព យើងអាចសន្និដ្ឋានបានពីកម្ពស់ទឹកភ្លៀង សីតុណ្ហភាព និង អាកាសធាតុនៃតំបន់ទាំងនោះ ។

## មេរៀនទី៨

# ក្នុងបរិយាកាស ពពក និងកំណាកអាកាស

**សំណួរ១ តើមានអ្វីខុសគ្នារវាងសំណើមនិងសំណើមប្រៀបធៀប ?**

**ចម្លើយ:** វាងសំណើមនិងសំណើមប្រៀបធៀបមានលក្ខណៈ

ខុសគ្នាដូចជា៖

សំណើម គឺជាចំហាយទឹកដែលទទួលបានពីការរំហួត នៃទឹកនៅលើផែនដីគឺបានពី មហាសមុទ្រ បឹងទន្លេ ដី រុក្ខជាតិ និងសត្វ ។

សំណើមប្រៀបធៀបមាន ជាផលធៀបរវាងទម្ងន់ ចំហាយទឹកនិងទម្ងន់ចំហាយទឹកដែលមានច្រើនបំផុត នៅក្នុងអាកាសក្នុងចំណុះស្មើគ្នា ហើយក្នុងលក្ខខណ្ឌ សីតុណ្ហភាព និងសម្ពាធដូចគ្នា ។

**សំណួរ២ តើពពកកើតឡើងដូចម្តេច ?**

**ចម្លើយ:** ពពកកើតឡើងដោយសារ ខ្យល់អណ្តែតឡើងលើ ហើយចុះត្រជាក់ក្លាយជាខ្យល់ឆ្អែតចំហាយទឹក ដែលរួមជា

មួយ ល្អងធូលី ផ្សែង និងក្រាមអំបិល បង្កើតបានជាពពក ហោះអណ្តែតលើអាកាស ។

**សំណួរ៧ ហេតុអ្វីបានជាមានពពកខ្លះបង្កើតបានជាតំណក់ទឹកហើយខ្លះទៀត បង្កើតបានជាទឹកកកគ្រីស្តាល់ ?**

**ចម្លើយ:** បានជាពពកខ្លះ បង្កើតបានជាដំណក់ទឹកនិងខ្លះទៀត បង្កើតបានជាដុំទឹកកកគ្រីស្តាល់ពី ព្រោះវាអាស្រ័យទៅនឹងសីតុណ្ហភាពនៃពពកបើកាលណាសីតុណ្ហភាពពពកចុះត្រជាក់ខ្លាំងវាបណ្តាលឲ្យចំហាយនៅក្នុងពពកកក្លាយជាទឹកកកគ្រីស្តាល់ ។

**សំណួរ៨ តើភ្លៀងកើតឡើងយ៉ាងដូចម្តេច ? ចូររៀបរាប់ ។**

**ចម្លើយ:**ភ្លៀងកើតឡើងដោយសារ ដំណក់ទឹកតូចៗនៅក្នុងពពករីកកាន់តែធំឡើងៗ មិនអាចអណ្តែតនៅក្នុងបរិយាកាសបានធ្លាក់មកលើផែនដីក្លាយជាភ្លៀង ហើយមុនពេលដែលវាធ្លាក់មកលើផែនដី បានវាត្រូវរីកទំហំប្រហែល $2\times10^{-1}cm$ ទើបវាអាចធ្លាក់ចុះមកបាន ។

**សំណួរ៩ បើសិនបើសីតុណ្ហភាព និងចំនួនចំហាយទឹកក្នុង**

**ខ្យល់ប្រែប្រួលតើសំណើមប្រៀបធៀបស្ថិតនៅ ដដែលឬទេ ? ចូរពន្យល់ ។**

**ចម្លើយ:**បើសិនជា សីតុណ្ហភាពនិងចំនួនចំហាយក្នុងខ្យល់ប្រែប្រួលវានឹងបណ្តាលឲ្យសំណើមប្រៀបធៀបប្រែប្រួល ពីព្រោះ សំណើមប្រៀបធៀបមាន ជាផលធៀបរវាងទម្ងន់ចំហាយទឹក និងទម្ងន់ចំហាយទឹកដែលមានច្រើនបំផុតនៅក្នុងអាកាស ក្នុងចំណុះស្មើគ្នាហើយក្នុងលក្ខខណ្ឌសីតុណ្ហភាព និងសម្ពាធដូចគ្នាបើកាលណាមានការប្រែលប្រួលនូវធាតុបន្សំណាមួយ វានឹងបណ្តាលឲ្យសំណើមប្រៀបធៀបប្រែប្រួលភ្លាម។

មេរៀនទី៩

## គំរូធាតុអាកាស និងធាតុអាកាសនៅកម្ពុជា

**សំណួរ១ តើកត្តាអ្វីខ្លះ ដែលជះឥទ្ធិពលលើសម្ពាធអាកាស ?**

**ចម្លើយ:**កត្តាដែលជះឥទ្ធិពលដល់សម្ពាធបរិយាកាសរួមមាន៖ រយៈកម្ពស់ សីតុណ្ហភាព សំណើមអាកាស បណ្តុំខ្យល់ជាដើម ។

**សំណួរ២ ហេតុអ្វីបានជាខ្យល់មិនបក់ត្រង់ ពីមណ្ឌលសម្ពាធខ្លាំងទៅមណ្ឌលសម្ពាធខ្សោយ ?**

**ចម្លើយ:**បានជាខ្យល់មិនបក់ត្រង់ពីមណ្ឌលមានសម្ពាធខ្លាំងមកមណ្ឌលមានសម្ពាធខ្សោយ ពីព្រោះខ្យល់តែងតែរេទៅតាមកម្លាំង ផែនដីវិល ។

**សំណួរ៣ តើកត្តាអ្វីខ្លះដែលធ្វើឱ្យមានការប្រែប្រួល រំភាយកាំរស្មីព្រះអាទិត្យមកលើផែនដី ?**

**ចម្លើយ:** កត្តាដែលធ្វើឲ្យមានការប្រែប្រួលរំភាយកាំរស្មីព្រះអា

ទិត្យមានដូចជា ៖

➢ ចំណោតកាំរស្មីព្រះអាទិត្យមកលើផែនដី តែងតែប្រែប្រួល ទៅតាមតំបន់និងរដូវផ្សេងៗ លើពិភពលោក ។

➢ រយៈពេលថ្ងៃចាំងមកលើផែនដី ប្រែប្រួលទៅតាមចំនួនម៉ោងក្នុងពេលថ្ងៃនិងចំនួនម៉ោងក្នុងពេលយប់ ។

មេរៀនទី១០

## ឬាតុឬធាតុអាកាស

**សំណួរ១ ដូចម្ដេចហៅថា ម៉ាសខ្យល់ ? ព្រំខ្យល់ ?**

**ចម្លើយ:** ម៉ាសខ្យល់និងព្រំខ្យល់គឺ៖

ម៉ាសខ្យល់ គឺជាសំណើមនិងសីតុណ្ហភាពដែលបានពីតំបន់ម៉ាសខ្យល់នោះកកើត ។

ព្រំខ្យល់ គឺជាសំណើមនិងសីតុណ្ហភាព ហើយម៉ាសខ្យល់មួយៗមិនអាចលាយចូលគ្នាបានទេ ហើយនៅពេលម៉ាសខ្យល់ពីរជួបគ្នាបង្កើតបានជាព្រំខ្យល់ ។

**សំណួរ២ រៀបរាប់ពីភាពខុសគ្នានៃព្រំខ្យល់ក្ដៅនិងព្រំខ្យល់ត្រជាក់ ។**

**ចម្លើយ:** ព្រំខ្យល់ក្ដៅនិងព្រំខ្យល់ត្រជាក់ខុសគ្នាដូចជា៖

ព្រំខ្យល់ក្ដៅ ព្រំខ្យល់ក្ដៅកើតឡើងនៅពេលនៅពេលម៉ាសខ្យល់ក្ដៅបានជួប និងបក់ពីលើម៉ាសខ្យល់ត្រជាក់ជាទូទៅព្រំខ្យល់ក្ដៅនាំភ្លៀងនិងរលឹមមកជាមួយផង។បន្ទាប់ពីព្រំនេះទៅផុតធាតុអាកាសប្រែក្ដៅនិងស្រឡះហើយក្ដៅ

ព្រំខ្យល់ត្រជាក់ ម៉ាសខ្យល់ត្រជាក់ជួបនិងចូលជំនួស ម៉ាសខ្យល់ក្តៅ ព្រោះខ្យល់ត្រជាក់ធ្ងន់ធ្វើចលនាក្រោមខ្យលក្តៅស្រាលនិងរុញវាឡើងលើ ។ ព្រំខ្យល់ត្រជាក់អាចធ្វើចលនាលឿន បង្កឲ្យមានព្យុះភ្លៀង ភ្លៀង ឬព្រិល ។ ធាតុអាកាសត្រជាក់តែងតែ កើតឡើងនៅ តាមព្រំខ្យល់ត្រជាក់ ព្រោះខ្យល់ក្តៅត្រូវបានរុញចេញ ឆ្ងាយពីផ្ទៃផែនដី

**សំណួរ៣ បើយើងឮសម្លេងផ្គរ ១២វិនាទីក្រោយផ្លេកបន្ទោរ តើព្យុះភ្លៀងមានចម្ងាយប៉ុន្មាន ?**

**ចម្លើយ:** រកចម្ងាយព្យុះភ្លៀងពេលលឺសំឡេងផ្គរ 12 វិនាទីក្រោយផ្លេកបន្ទោរ

តាមម្រាប់: គេលឺសំលេងផ្គរ 12វិនាទីក្រោយផ្លេកបន្ទោរ

ដោយ 1s = 3km គេបាន

ចម្ងាយព្យុះភ្លៀង = 12/3 = 4 km

ដូចនេះ ចម្ងាយព្យុះភ្លៀងគឺ $=4km$

**សំណួរ៤ បើយើងឮសម្លេងផ្គរ ៣៦វិនាទីក្រោយផ្លេកបន្ទោរ តើ**

**ព្យុះភ្លៀងមាន ចម្ងាយប៉ុន្មាន ?**

**ចម្លើយ:** រកចម្ងាយព្យុះភ្លៀងពេលលឺសំឡេងផ្គរ 36 វិនាទី ក្រោយផ្លេកបន្ទោរ

តាមម្រាប់: គេលឺសំលេងផ្គរ 36វិនាទីក្រោយ ផ្លេកបន្ទោរ

ដោយ 1s = 3 km គេបាន

ចម្ងាយព្យុះ = 36/3 = 12 km

ដូចនេះ ចម្ងាយព្យុះភ្លៀងគឺ = 12 km ។

**សំណួរ៨ ចូរពន្យល់ តើហ្វូរីកានកើតឡើងយ៉ាងដូចម្ដេច ?**

**ចម្លើយ: ហ្វូរីកាន** កើតឡើងដោយសារ ចាប់ផ្ដើមពីក្រុមមួយនៃព្យុះភ្លៀង ធ្វើចលនាលើទឹកសមុទ្រក្នុងតំបន់ត្រូពិច ។ ខ្យល់បក់ចេញពីទិសដៅពីរផ្សេងគ្នាបានប៉ះគ្នា បណ្ដាលឲ្យមានព្យុះគួចនៅលើតំបន់សម្ពាធខ្សោយ ។ វាបានទទួលថាមពល ពីកំណកនៃចំហាយទឹក ដែលមានទំនាក់ទំនងជាមួយទឹកមហាសមុទ្រក្ដៅ ខ្យល់ក្ដៅមានផ្ទុកចំហាយទឹក ជាច្រើនបានពីការរំហួតពីទឹក សមុទ្រ នៅពេលខ្យល់ក្ដៅហោះឡើងលើចំហាយ ទឹក

កករួច បញ្ចេញថាមពល យ៉ាងកខ្លាំង បង្កើតបានជា ព្យុះហ៊ូរីកាន ។

## មេរៀនទី១១

## ការព្យាករធាតុអាកាស និងការប្រែប្រួលអាកាសធាតុ

**សំណួរ១ តើឧតុភូតវិទូប្រមូលទិន្នន័យធាតុអាកាសតាមវិធីអ្វីខ្លះ? ប្រមូលដើម្បីអ្វី ?**

**ចម្លើយ:** អ្នកឧតុភូតវិទូប្រមូលទិន្នន័យធាតុអាកាសតាមរយះ:

- ការបង្ហោះបាល់ឡុងដែលមានផ្ទុក ឧបករណ៍ដើម្បីកត់ត្រាពីសីតុណ្ហភាព សំណើម និងសម្ពាធអាកាស ។
- ទីតាំងស្ថានីលើដីបានរួមចំណែកយ៉ាងសំខាន់ក្នុង ការប្រមូលនិងកត់ត្រាទិន្នន័យធាតុអាកាស ។
- អ្នកបើកយន្តហោះ រួមចំណែកក្នុងការរាយការណ៍ពីលក្ខណៈខ្យល់នៅរយះកម្ពស់ខ្ពស់
- ការបង្ហោះតារាវណាប និងប្រើប្រព័ន្ធរ៉ាដា ក្នុងការប្រ មូលពត៌មានសំខាន់ៗពីធាតុអាកាស ។

**សំណួរ២ តើការព្យាការធាតុអាកាសត្រូវបានគេផ្សព្វផ្សាយតាមរយៈអ្វីខ្លះ ?**

**ចម្លើយ:** ការព្យាករធាតុអាកាសត្រូវបានផ្សព្វផ្សាយតាមរយៈ វិទ្យុទូរទស្សន៍ ការសែត និងប្រភពផ្តល់ព័តិមានផ្សេងៗទៀតជាច្រើន ។

**សំណួរ៣ តើមានកត្តាអ្វីខ្លះដែលបណ្តាលឱ្យ មានការប្រែ ប្រួលអាកាសធាតុ ?**

**ចម្លើយ:** អ្នកវិទ្យាសាស្ត្រមិនទាន់កំណត់បានថា កត្តាអ្វីដែលធ្វើឲ្យប៉ះពាល់ដល់ការ ប្រែប្រួលអាកាសធាតុនៅឡើយទេ តែបើតាម ការសង្កេតវាអាចបណ្តាលមកពីការកើនឡើងនៃ *ឧស្ម័នផ្ទះកញ្ចក់ ការបំផ្លាញស្រទាប់អូសូន និងការកើនឡើងយ៉ាងច្រើន នៃចំនួន ប្រជាជន* ដែលបានការប្រើប្រាស់នូវធនធានធម្មជាតិកាន់តែច្រើន ម៉្យាងទៀតមនុស្សបានប្រើប្រាស់ និងបញ្ចេញសារធាតុ គីមីពុលផ្សេងៗដែលប៉ះពាល់ការប្រែប្រួលអាកាសធាតុ ឬអា កាសធាតុប្រែប្រួល

អាចបណ្តាលមកពីការវិវត្តរបស់ធម្មជាតិឬយ៉ាងណា។



## មេរៀនទី១២

# កង្វក់ឬការបំពុលខ្យល់

**សំណួរ១ តើកត្តាអ្វីខ្លះ ដែលបង្កឱ្យមានការបំពុលខ្យល់ ?**

**ចម្លើយ:** កត្តាដែលធ្វើឲ្យមានការបំពុលខ្យល់មាន៖

❖ភាគល្អិត មានធូលីនិងអ័ព្ទ

❖អាសូតអុកស៊ីត មាន អាសូតម៉ូណូអុកស៊ីត ($NO$) អាសូតឌីអុកស៊ីត ($NO_2$) ឌីអាសូតម៉ូណូអុកស៊ីត($N_2O$)

❖ស្ពាន់ធ័រឌីអុកស៊ីត ($SO_2$)

❖កាបូន ម៉ូណូអុកស៊ីត($CO$)

❖កាបូនឌីអុកស៊ីត ឬឧស្ម័នកាបូនិច($CO_2$)

❖អ៊ីដ្រូកាបួ វាផ្សំឡើងពី អ៊ីដ្រូសែននិងកាបូន

❖អូសូនក្នុងមណ្ឌលអាកាសរចល់ ($O_3$)

❖ស្មុកផូតូគីមី វាកើតឡើងពីការបន្សំចូលគ្នានៃផ្សែងពុល ជាច្រើន មានប្រភពចេញពីទីក្រុងនានា ។

**សំណួរ២ ចូររៀបរាប់ពីផលប៉ះពាល់ នៃការបំពុលខ្យល់លើ សុខភាពមនុស្ស ។**

**ចម្លើយ:**

ផលប៉ះពាល់ដែលបណ្ដាលមកពីការបំពុលខ្យល់មាន ៖

❖ភាគល្អិត និងជម្ងឺផ្កែក ។

❖អាសូតអុកស៊ីត បណ្ដាលឲ្យមានជំងឺផ្លូវដង្ហើមនិងបង្អាក់ការលូតលាស់របស់រុក្ខជាតិ

❖ស្ពាន់ធ័រឌីអុកស៊ីត ($SO_2$)បណ្ដាលឲ្យមានជំងឺផ្លូវដង្ហើម បេះដូងរាំរ៉ៃ ជម្ងឺស្ទួត និងរលាកទងសួត

❖កាបូនម៉ូណូអុកស៊ីត($CO$) បណ្ដាលឲ្យឈឺក្បាល វិលមុខ ងុយដេក និងមានជំងឺបេះដូង

❖អ៊ីដ្រូកាបួ វាអាចបំផ្លាញផ្លូវដង្ហើមនិងកើតមហារីក

❖ស្មុកផូតូគីមី បណ្ដាលឲ្យក្អក រួមផ្លូវដង្ហើម ក្រហាយប្រព័ន្ធដកដង្ហើម ផ្សាភ្នែក និងអាចបណ្ដាលឲ្យកើតជំងឺ

មហារីកផងដែរ

❖ សំណ ធ្វើឥឲ្យមានការរាំងស្ទះដល់ការរីកចំរើនលើផ្នែកប្រាជ្ញាស្មារតីរបស់កុមារ ។

**សំណួរ៣ ចូររៀបរាប់ឈ្មោះសារធាតុបំពុលខ្យល់ឱ្យបាន៥ ។**

**ចម្លើយ:** សារធាតុបំពុលចំនួន 5 គឺ

✓ អាសូតអុកស៊ីត មាន អាសូតម៉ូណូអុកស៊ីត ($NO$)

✓ អាសូតឌីអុកស៊ីត ($NO_2$) ឌីអាសូតម៉ូណូអុកស៊ីត($N_2O$)

✓ ស្ពាន់ធ័រឌីអុកស៊ីត ($SO_2$)

✓ កាបូន ម៉ូណូអុកស៊ីត($CO$)

✓ កាបូនឌីអុកស៊ីតឬឧស្ម័នកាបូនិច($CO_2$)អ៊ីដ្រូកាបួ វាផ្សំឡើងពី អ៊ីដ្រូសែននិងកាបូន ។

**សំណួរ៤ ដើម្បីទប់ស្កាត់គ្រោះថ្នាក់មកលើសុខភាពមនុស្សលើពិភពលោក ក៏ ដូចជាខ្លួនយើងផ្ទាល់ តើយើងអាចធ្វើកិច្ចការអ្វីខ្លះ ដើម្បីកាត់បន្ថយកា បំពុលខ្យល់ ?**

**ចម្លើយ:** ដើម្បីទប់ស្កាត់ គ្រោះថ្នាក់មកលើសុខភាពមនុស្សលើពិ

ភាពលោកនិងរូបយើងផ្ទាល់យើងត្រូវមានវិធានការ ដូចខាងក្រោម៖

❖ កាត់បន្ថយការ ប្រើប្រាស់ប្រេងសាំងមានជាតិសំណច្រើន ប្រេងកាតមានជាតិស្ពាន់ធ័រទាបនិងរថយន្តចាស់ៗនៅតាមដងផ្លូវសាធារណៈ លើកទឹកចិត្តដល់ប្រជាជនឲ្យមានការធ្វើដំណើរតាមថ្មើរជើង និងទោចក្រយានយន្ត។

❖ ដាំដើមឈើឲ្យបានច្រើននៅតាមដងផ្លូវមមាញឹក ព្រោះវាអាចស្រូបធូលីនិងឧស្ម័នពុលផ្សេងៗ ដែលចេញពីរថយន្ត។

❖ តំបន់ឧស្សាហកម្មនិងកន្លែងចាក់សំរាម ត្រូវនៅឆ្ងាយពីទីប្រជុំជនឬទីក្រុងហើយនៅក្រោមខ្យល់ ។

❖ សង់ផ្លូវធំៗនិងអគារទាបៗជៀសវាងការប្រមូលផ្តុំនូវសារធាតុពុលមានកម្រិតខ្ពស់ ។

❖សង់បំពង់ផ្សែងរោងចក្រ ដោយប្រើប្រាស់បច្ចេកវិទ្យាកាត់បន្ថយឧស្ម័ននិងផ្សែងពុលឲ្យបានត្រឹមត្រូវ ។

❖ប្រើប្រាស់បច្ចេកវិទ្យា ទំនើបក្នុងការត្រួតពិនិត្យឧស្ម័ន ពុល

ទាំងឡាយ ។

❖អនុវត្តច្បាប់យកពន្ធលើការបញ្ចេញឧស្ម័នពុលផ្សេង ពីសំណាក់រោងចក្រសហគ្រាស និងយានយន្តចាស់ៗ ជាដើម ។

## សំណួរបញ្ចប់ជំពូកទីពាចម្លើយ

I. គូសញ្ញា ✓ នៅមុខចម្លើយត្រឹមត្រូវ

១. ឧស្ម័នដែលមានច្រើនជាងគេបំផុតនៅក្នុងខ្យល់គឺ

☐ ក. អុកស៊ីសែន ☐ ខ. នីត្រូសែន

☐ គ. អ៊ីដ្រូសែន ☐ ឃ. កាបូនឌីអុកស៊ីត ។

២. ប្រភពចម្បងរបស់អុកស៊ីសែននៃបរិយាកាសផែនដីគឺ

☐ ក. ទឹកសមុទ្រ ☐ ខ. ព្រះអាទិត្យ

☐ គ. រុក្ខជាតិ ☐ ឃ. សត្វ ។

៣. ស្រទាប់បរិកាសដែលនៅក្រោមគេបំផុត ជាកន្លែងដែលធាតុអាកាសទាំងអស់កើតឡើងគឺ

☐ ក. មណ្ឌលអាកាសស្ងប់ ☐ ខ. មណ្ឌលអាកាសរចល់

☐ គ. មណ្ឌលកម្ដៅ ☐ ឃ. មណ្ឌលកណ្ដាល ។

៤. ថាមពលព្រះអាទិត្យដែលមកដល់បរិយាកាសខាងក្រៅ ត្រូវបានស្រូប យកនៅលើផ្ទៃផែនដីប្រហែល

☐ ក. 20% ☐ ខ. 30%

☐ គ. 50% ☐ ឃ. 70% ។

៥. ស្រទាប់អូសូនស្ថិតនៅក្នុង

☐ ក. មណ្ឌលអាកាសស្ងប់ ☐ ខ. មណ្ឌលអាកាសរចល់

☐ គ. មណ្ឌលកម្ដៅ ☐ ឃ. មណ្ឌលកណ្ដាល ។

៦. ថាមពលកម្ដៅភាគច្រើននៅក្នុងបរិយាកាសធ្វើចលនាតាមរយៈ

☐ ក. ចម្លងកម្ដៅ ☐ ខ. រង្វល់

☐ គ. លំនាំនៃការបញ្ជូនលក្ខណៈបរិយាកាសដោយខ្យល់បក់

☐ ឃ. រំភាយរស្មី ។

៧. តុល្យភាពរវាងថាមពលដែលមកដល់ផ្ទៃផែនដីនិងថាមពលផ្លាតចេញ ពីផ្ទៃផែនដីត្រូវបានហៅថា

☐ ក. រង្វល់ ☐ ខ. ចម្លងកម្ដៅ

☐ គ. ផលផ្ទះកញ្ចក់ ☐ ឃ. តុល្យភាពរំភាយស្មើ ។

## II. សំណួរ

១. ហេតុអ្វីបានជាបរិយាកាសមានកាន់តែស្រាលទៅៗ នៅពេលរយៈកម្ពស់កើនឡើង ?

២. តើអ្វីជាមូលហេតុធ្វើឱ្យសីតុណ្ហភាពប្រែប្រួលនៅក្នុងបរិយាកាស ?

# ចម្លើយបញ្ចប់ជំពូកទី៣

## I. គូសញ្ញា ✓ នៅមុខចម្លើយត្រឹមត្រូវ

១. ឧស្ម័នដែលមានច្រើនជាងគេបំផុតនៅក្នុងខ្យល់គឺ

☑ **ក. អុកស៊ីសែន** ☐ ខ. នីត្រូសែន

☐ គ. អ៊ីដ្រូសែន ☐ ឃ. កាបូនឌីអុកស៊ីត ។

២. ប្រភពចម្បងរបស់អុកស៊ីសែននៃបរិយាកាសផែនដីគឺ

☐ ក. ទឹកសមុទ្រ ☐ ខ. ព្រះអាទិត្យ

☑ **គ. រុក្ខជាតិ** ☐ ឃ. សត្វ ។

៣. ស្រទាប់បរិកាសដែលនៅក្រោមគេបំផុត ជាកន្លែង

ដែលធាតុអាកាសទាំងអស់កើតឡើងគឺ

☐ ក. មណ្ឌលអាកាសស្ងប់ ☑ **ខ.មណ្ឌលអាកាសរចល់**

☐ គ. មណ្ឌលកម្តៅ ☐ ឃ. មណ្ឌលកណ្តាល ។

៤. ថាមពលព្រះអាទិត្យដែលមកដល់បរិយាកាសខាងក្រៅត្រូវបានស្រូបយកនៅលើផ្ទៃផែនដីប្រហែល

☐ ក. 20% ☐ ខ. 30%

☐ គ. 50% ☑ **ឃ.** 70% ។

៥. ស្រទាប់អូសូនស្ថិតនៅក្នុង

☑ **ក. មណ្ឌលអាកាសស្ងប់** ☐ ខ. មណ្ឌលអាកាសរចល់

☐ គ. មណ្ឌលកម្តៅ ☐ ឃ. មណ្ឌលកណ្តាល ។

៦. ថាមពលកម្តៅភាគច្រើននៅក្នុងបរិយាកាសធ្វើចលនាតាមរយៈ

☑ **ក. ចម្លងកម្តៅ**

☐ ខ. រង្វល់

☐ គ. លំនាំនៃការបញ្ជូនលក្ខណៈបរិយាកាសដោយខ្យល់បក់

☐ឃ. វិភាយរស្មី ។

៧. តុល្យភាពរវាងថាមពលដែលមកដល់ផ្ទៃផែនដីនិងថាមពលផ្លាតចេញពីផ្ទៃផែនដីត្រូវបានហៅថា

☐ក. រង្វាល់ ☐ខ. ចម្លងកម្តៅ

☐គ. ផលផ្ទះកញ្ចក់ ☑**ឃ. តុល្យភាពវិភាយស្មើ.**

## II. សំណួរនិងចម្លើយ

1.បានជាបរិយាកាសមានកាន់តែស្រាលនៅពេល នៅពេលរយៈកម្ពស់កើនឡើង ពីព្រោះកម្ពស់កាន់តែខ្ពស់ម៉ូលេគុលខ្យល់ និងម៉ូលេគុលឧស្ម័នផ្សេងៗក្នុងបរិយាកាសមានកាន់តែតិចធ្វើឲ្យ បរិយាកាសកាន់តែស្រាលនៅ ពេលកម្ពស់កាន់តែខ្ពស់ ។

2. សីតុណ្ហភាពប្រែប្រួលក្នុងបរិយាកាស បណ្តាលមកពី ការប្រែប្រួលនៃរយៈកម្ពស់នៅលើផែនដី វាប្រែប្រែប្រួលក្រោមលក្ខខ័ណ្ឌក្តៅ ឬត្រជាក់ ។

# ជំពូកទី ៨ បរិស្ថាន

## មេរៀនទី ១ ការស្វែងយល់ពីបរិស្ថាន

**សំណួរ១ តើបរិស្ថានជាអ្វី ? មានប៉ុន្មានផ្នែក ?ចូរពណ៌នា ។**

**ចម្លើយ:**បរិស្ថានជាអ្វីដែលនៅព័ទ្ធជុំវិញខ្លួនយើងរួមទាំងខ្លួនយើងមានដូចជា មនុស្ស សត្វ ធម្មជាតិទាំងឡាយជាដើម ។ គេចែកបរិស្ថានជាពីរផ្នែកគឺ ៖

បរិស្ថានធម្មជាតិ មានដូចជា បរិស្ថានរូប ( កក្កាដី ទឹក និងអាកាសធាតុ ) និងបរិស្ថានជីវៈ (មនុស្ស សត្វ និង រុក្ខជាតិ ) ។

បរិស្ថានសង្គម-វប្បធម៌ មានដូចជាអគារ រោងចក្រ ផ្លូវ ថ្នល់ជាដើម ។

**សំណួរ២ តើសកម្មភាពមនុស្សមានឥទ្ធិពលទៅលើបរិស្ថានដូចម្តេចខ្លះ ?**

**ចម្លើយ:** សកម្មភាពមនុស្សមានឥទ្ធិពលលើបរិស្ថានដូចជា៖

យើងទាញយកធនធានពីបរិស្ថានដូចជា ទឹកស្អាត រ៉ែ ត្រី ព្រៃឈើ...។ល។យើងបញ្ចេញចោលរបស់ខ្លះ ទៅក្នុងបរិស្ថានវិញដូចជា ផ្សែង សំណល់ចេញពីរោងចក្រ ប្លាស្ទិច ...។ល ។ យើងជំនួសបរិស្ថានធម្មជាតិ ដោយអ្វីមួយផ្សេងទៀត ដូចជាការកាប់ព្រៃ តែជំនួសដោយការសង់រោងចក្រ អគារពាណិជ្ជកម្ម ...។ល ។

**សំណួរ៣ បើយើងបំផ្លាញធម្មជាតិឬទាញយកផលពីបរិស្ថានច្រើនហួសហេតុពេក តើវានឹងផ្តល់ផលប៉ះពាល់អ្វីខ្លះ ដល់យើង នាពេលអនាគត ?**

**ចម្លើយ:** បើយើងបំផ្លាញធនធានធម្មជាតិឬទាញយកផលពីបរិស្ថានច្រើនហួសហេតុពេក វានឹងផ្តល់ផលប៉ះពាល់ចំពោះសង្គមមនុស្សទៅថ្ងៃអនាគតដូចជា ៖

បាត់បង់និរន្តរភាពបរិស្ថាន ការកើនឡើងនូវឧស្ម័នផ្ទះកញ្ចក់ ជួបប្រទះគ្រោះធម្មជាតិធ្ងន់ធ្ងរ (ទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ ឡើងកម្តៅផែនដី ... )

នេះគ្រាន់តែជាផ្នែកមួយតូច នៃផលប៉ះពាល់ចំពោះមនុស្ស នៅថ្ងៃអនាគត ពេលយើងប្រើប្រាស់បរិស្ថានច្រើនហួសកម្រិត ឬការបំផ្លិចបំផ្លាញបរិស្ថានមានកម្រិតខ្ពស់។យើងត្រូវចងចាំ

"បើកាលណាយើងបំផ្លាញបរិស្ថាន
នោះបរិស្ថាននឹងបំផ្លាញយើងវិញ " ។

# មេរៀនទី២ ស្ថានប្រព័ន្ធ

**សំណួរ១ តើស្ថានប្រព័ន្ធជាអ្វី ? មានធាតុផ្សំអ្វីខ្លះ ?**

**ចម្លើយ:**ស្ថានប្រព័ន្ធជាសំណុំសារពាង្គកាយ ដែលមានជីវិតទាំងអស់រួមជាមួយមជ្ឈដ្ឋានជីវិតនិងមានអំពើទៅលើគ្នាទៅវិញទៅមករវាងសារពាង្គកាយមានជីវិតទាំងនោះ ជាមួយមជ្ឈដ្ឋានជីវិតរបស់វាដែលស្ថិតនៅកន្លែងមួយកំណត់ ។ វាមានធាតុផ្សំពីមានជីវិត(សត្វ រុក្ខជាតិនិងមីក្រូសារពាង្គកាយ ) និងគ្មានជីវិត ( ពន្លឺព្រះអាទិត្យ ខ្យល់ ដី ទឹក ភ្លើង... ) ។

**សំណួរ២ តើស្ថានប្រព័ន្ធសំខាន់ៗនៅប្រទេសកម្ពុជាមានអ្វីខ្លះ ?**

**ចម្លើយ:** ស្ថានប្រព័ន្ធសំខាន់ៗនៅប្រទេសកម្ពុជាមានដូចជា

- ❖ស្ថានប្រព័ន្ធបឹងទន្លេសាប
- ❖ស្ថានប្រព័ន្ធ ប្រព័ន្ធទន្លេមេគង្គ
- ❖ស្ថានប្រព័ន្ធតំបន់ឆ្នេរ
- ❖ស្ថានប្រព័ន្ធព្រៃឈើ ។

**សំណួរ៣ តើហេតុអ្វីបានជាគេចាត់ទុកបឹងទន្លេសាបជា" បេតិកភណ្ឌពិភពលោក"**

**ចម្លើយៈ**បានជាគេចាត់ទុក បឹងទន្លេសាបជាបេតិកភណ្ឌពិភពលោកពីព្រោះ បឹងទន្លេសាបបានបម្រើនិងមាននាទីយ៉ាង សំខាន់ដល់វិស័យសេដ្ឋកិច្ចសង្គម និងវប្បធម៌របស់ប្រជាជនយើង ហើយវាជាប្រភពនៃជីវៈចម្រុះយ៉ាងសម្បូរបែប និងជាបឹងធម្មជាតិពិតៗ ។

**សំណួរ៤ តើនានាភាពនៃជីវៈចម្រុះមានអ្វីខ្លះ ?**

**ចម្លើយៈ** នានាភាពនៃជីវៈចម្រុះមានដូចជា សត្វ រុក្ខជាតិ មីក្រូសារពាង្គកាយនិងរូបធាតុ សែន ព្រមទាំងស្ថានប្រព័ន្ធផងដែរ ។

## មេរៀនទី៣

# ប្រវត្តិនៃការប្រែប្រួលបរិស្ថានពិភពលោក

**សំណួរ១ តើគេចែកអាយុផែនដីដូចម្តេច ?**

**ចម្លើយ:**គេចែកអាយុរបស់ផែនដីបាន ដោយសារការវិវត្ត របស់ ស័កមានដូចជា

- ស័កប៉ាលេអូសូអ៊ិច (Palozoic Era) មាន6សម័យកាលគឺ កំប្រីយាង អរដូវីស្យាង ស៊ីលួរ្យាង ដេវ៉ូនីញ៉ោង កាបូនីផែ និងពែមីញ៉ោង ។
- ស័កមេសូសូអ៊ិច(Mesozoic Era)មានសម័យទ្រីយ៉ាសស្ហូរ៉ាស៊ិច និងកាលសម័យក្រេតាសេ ។
- ស័កសេណូសូអ៊ិច (Cenozoic Era) វាមានពីរសម័យកាលគឺ ទែត្យារី និងក្វាទែណារី ។

**សំណួរ២ តើនៅក្នុងកំឡុងពេលមួយណាដែលដាយណូស័រ ត្រូវ**

**នាសសាបសូន្យ?**

**ចម្លើយ:**ក្នុងកំឡុងពេល ដែលដាយណូស័រត្រូវវិនាសសាបសូន្យគឺនៅចុងស័កមេសូអ៊ិច ។

**សំណួរ ៣ តើយុគសម័យទឹកកកនៅលើផែនដីកើតឡើងដោយសារអ្វី ?**

**ចម្លើយ:**យុគសម័យទឹកកកនៅលើផែនដីកើតឡើងដោយសារការប្រែប្រួលគន្លងផែនដីវិលជុំវិញព្រះអាទិត្យ ធ្វើឲ្យផែនដីចុះត្រជាក់ និងគ្របដោយកំរាលទឹកកក ។

# មេរៀនទី៨

## សកម្មភាពមនុស្ស និងការប្រែប្រួលបរិស្ថាន

**សំណួរ១ ចូររៀបរាប់ពីឥទ្ធិពលបីយ៉ាង នៃសកម្មភាពមនុស្ស ទៅលើបរិស្ថាន ។**

**ចម្លើយ:**ឥទ្ធពលបីយ៉ាងនៃសកម្មភាពមនុស្សមទៅលើបរិស្ថាន ដូចជា ៖

✓ មនុស្សទាញយកធនធានពីបរិស្ថានមនុស្សបញ្ចេញចោលរបស់ខ្លះទៅក្នុងបរិស្ថានវិញមនុស្សជំនួសបរិស្ថានធម្មជាតិដោយផ្សេងអ្វីមួយទៀត ។

**សំណួរ២ រាប់ឈ្មោះប្រភេទសំខាន់ទាំងបីនៃបញ្ហាបរិស្ថាននិងរកឧទាហរណ៍ បញ្ជាក់ពីប្រភេទនីមួយៗ ។**

**ចម្លើយ:**រាប់ឈ្មោះប្រភេទសំខាន់ៗទាំងបីនៃបរិស្ថានមានដូចជា:

ការថយចុះនៃធនធានធម្មជាតិ: ឧទាហរណ៍ ការប្រើប្រាស់

នូវបរិមាណយ៉ាងធំ នៃធនធានធម្មជាតិ ដូចជា ទឹក ដី ព្រៃឈើ ជាដើម។

កម្វក់: ឧទាហរណ៍ ការកើនឡើងនូវកាបូនម៉ូណូអុកស៊ីតធ្វើឲ្យប៉ះពាល់ដល់បរិយាកាស និងប្រភពបំពុលជាច្រើនទៀត ដូចជា ទឹកសំអុយ ថ្នាំសម្លាប់សត្វល្អិត ធាតុវិទ្យុសកម្ម សំលេងរំញ៉ូរ......។

ការវិនាសសាបសូន្យ ឧទាហរណ៍ ការកើនឡើងចំនួនប្រជាជនធ្វើឲ្យដីសម្រាប់សង់ទីជម្រកកាន់តែតិច និងការ កាប់បំផ្លាញព្រៃឈើជាដើម....។

**សំណួរ៣ ប្រៀបធៀបធនធានធម្មជាតិកើតឡើងវិញនិងមិនអាចកើតឡើងវិញ បានដោយលើឧទាហរណ៍បញ្ជាក់ ។**

**ចម្លើយ:** ប្រៀបធៀបធម្មជាតិកើតឡើងវិញ និងមិនកើតឡើងវិញ

+ធម្មជាតិកើតឡើងវិញ: ជាធនធានដែលអាចជំនួសឡើងវិញដោយធម្មជាតិ ឬដោយសកម្មភាពមនុស្សវាជាធនធានដែលប្រើប្រាស់មិនចេះរីងស្ងួត

ឧទាហរណ៍: ព្រៃឈើអាចដាំឡើងវិញបានក្រោយពីប្រមូលផលរួច....។

+ធម្មជាតិមិនកើតឡើងវិញ: ជាធនធានដែលអាចប្រើប្រាស់អស់ទាំងស្រុង ឬដល់កំរិតមួយដែលមិនអាចទាញយកមកប្រើប្រាស់វិញបាន ហើយមិនអាចកើតវិញជំនួសដោយធម្មជាតិ។

ឧទាហរណ៍ ផូស៊ីលឥន្ធនៈ ដូចជា ប្រេង ធ្យូងថ្ម ឧស្ម័នធម្មជាតិ ....។

**សំណួរ៨ ពណ៌នាពីសកម្មភាពមនុស្សដែលអាចផ្តល់និរន្តភាពដល់ពិភពលោក ។**

**ចម្លើយ:**សកម្មភាពដែល អាចផ្តល់និរន្តរភាពដល់ពិភពលោក មានដូចជា ជម្រកសត្វត្រូវបានគេការពារ សំណល់ ឬ សំរាមត្រូវបានគេកែឆ្នៃឡើងវិញឲ្យទៅជា សារធាតុគ្មានគ្រោះថ្នាក់។ ធនធានធម្មជាតិកើតឡើងវិញ ត្រូវប្រើប្រាស់ដោយ សន្សំសំចៃ និងមានប្រសិទ្ធភាពខ្ពស់បំផុត ហើយធនធានធម្មជាតិមិនកើតឡើងវិញត្រូវ ប្រើប្រាស់ឲ្យបានសមស្របតាមអ្វីដែលគេ

អាចយកមក បំពេញជំនួសបាន។

# លំហាត់បញ្ចប់ជំពូកទី៤

I. គូសញ្ញា ✓ នៅមុខចម្លើយត្រឹមត្រូវ

១. សារពាង្គកាយដែលមានប្រភេទដូចគ្នានិងមានអំពើលើគ្នាទៅវិញទៅមកហៅថា

☐ ក. បណ្តាភារៈ ☐ ខ. សហគមន៍

☐ គ. ជម្រក ☐ ឃ. ស្ថានប្រព័ន្ធ ។

២. ចំណុចមួយណា ដែលមានសារៈសំខាន់ដល់ការគ្រប់គ្រងជីវៈចម្រុះ ?

☐ ក. ការធ្វើឱ្យសត្វរំពារអាចគេចចេញពីសំបុកសត្វដទៃ

☐ ខ. ការធ្វើមិនឱ្យមានការបំពុលបរិស្ថាន

☐ គ. ការស្រាវជ្រាវដោយប្រុងប្រយ័ត្នមុនអនុវត្តន៍

☐ ឃ. ការសម្លាប់សត្វចង្រៃយ៉ាងឆាប់រហ័ស ។

៣. ទឹក ដី ខ្យល់ និងព្រះអាទិត្យជាធនធាន

☐ ក. ធម្មជាតិ

☐ ខ. ធម្មជាតិកើតឡើងវិញនិងមិនកើតឡើងវិញ

☐ គ. ធម្មជាតិកើតឡើងវិញ

☐ ឃ.ធម្មជាតិមិនកើតឡើងវិញ ។

II.ចូរបំពេញចន្លោះខាងក្រោមឲ្យបានត្រឹមត្រូវ

១. ចំហេះផូស៊ីសឥន្ធនៈបង្កឱ្យមាន ............................។

២. តំបន់ដែលត្រូវបានកំណត់ឡើងសម្រាប់អភិរក្សធនធានធម្មជាតិ ហៅ ថា ..................... ។

៣. ចូរបំពេញដ្យាក្រាមខាងក្រោម




### III. សំណួរ

១. ស្ថានប្រព័ន្ធនិងជីវៈចម្រុះជាអ្វី ?

២. ដាយណូស័រគ្របដណ្តប់លើផែនដីនៅពេលណា ? រយៈពេលប៉ុន្មានឆ្នាំ? វិនាសសាបសូន្យនៅពេលណា ?

៣. បក្សីនិងល្មូនបានវិវត្តន៍នៅក្នុងសម័យកាលណា ?

៤. ហេតុអ្វីបានជាពុំមានផូស៊ីលនៅក្នុងសិលាភ្នំភ្លើង ?

# ចម្លើយមេរៀនទី៤

I. គូសញ្ញា ✓ នៅមុខចម្លើយត្រឹមត្រូវ

១. សារពាង្គកាយដែលមានប្រភេទដូចគ្នានិងមានអំពើលើគ្នាទៅវិញទៅមកហៅថា

☑ ក. បណ្តាភាវៈ ☐ ខ. សហគមន៍

☐ គ. ជម្រក ☐ ឃ. ស្ថានប្រព័ន្ធ ។

២. ចំណុចមួយណា ដែលមានសារៈសំខាន់ដល់ការគ្រប់គ្រងជីវៈចម្រុះ ?

☐ក. ការធ្វើឱ្យសត្វរំពារអាចគេចចេញពីសំបុកសត្វដទៃ

☐ខ. ការធ្វើមិនឱ្យមានការបំពុលបរិស្ថាន

☑គ. ការស្រាវជ្រាវដោយប្រុងប្រយ័ត្នមុនអនុវត្តន៍

☐ឃ. ការសម្លាប់សត្វចង្រៃយ៉ាងឆាប់រហ័ស ។

៣. ទឹក ដី ខ្យល់ និងព្រះអាទិត្យជាធនធាន

☑**ក. ធម្មជាតិ**

☐ខ. ធម្មជាតិកើតឡើងវិញនិងមិនកើតឡើងវិញ

☐គ. ធម្មជាតិកើតឡើងវិញ

☐ឃ.ធម្មជាតិមិនកើតឡើងវិញ ។

II. ចូរបំពេញចន្លោះខាងក្រោមឲ្យបានត្រឹមត្រូវ

១.ចំហេះផូស៊ីលឥន្ធនៈបង្កឱ្យមាន កំណើនបំពុលខ្យល់

២.តំបន់ដែលត្រូវបានកំណត់ឡើងសម្រាប់អភិរក្សធនធានធម្មជាតិហៅថា ឧទ្យានជាតិ ។

**៣.ចូរបំពេញផ្សាក្រាមខាងក្រោម**




## III. ចម្លើយ

1. ស្ថានប្រព័ន្ធនិងជីវៈចម្រុះជា

• ស្ថានប្រព័ន្ធ ជាសំណុំសារពាង្គកាយដែលមានជីវិតទាំងអស់រួមជាមួយមជ្ឈដ្ឋានជីវិតនិងមានអំពើទៅលើគ្នាទៅវិញទៅមករវាងសារពាង្គកាយមានជីវិតទាំងនោះ ជាមួយ

មជ្ឈដ្ឋានជីវិតរបស់វាដែលស្ថិតនៅកន្លែងមួយកំណត់ ។

- **ជីវៈចម្រុះ** ជានានាភាពនៃជីវិតនៅលើផែនដី មានដូចជាសត្វ រុក្ខជាតិ មីក្រូសារពាង្គកាយនិងរូបធាតុ សែន ព្រមទាំងស្ថានប្រព័ន្ធផងដែរ ។

2. ដាយណូស័រគ្របដណ្តប់នៅលើផែនដីនៅកាលសម័យទ្រីយ៉ាស ។វាបានគ្របដណ្តប់លើផែនដីជាង100លានឆ្នាំ និងវិនាសសាបសូន្យនៅចុងស័កមេសូសូអ៊ិច ។

3. បក្សីនិងល្មូនបានវិវត្តន៍ក្នុងកាលសម័យសូរ៉ាស៊ិចក្នុងស័កមេសូសូអ៊ិច ។

4. បានជាពុំមានផូស៊ីល់ក្នុងសិលាភ្នំភ្លើង ពីព្រោះម៉ាក់ម៉ាក្តៅវាធ្វើឲ្យឆេះគ្រប់អ្វីៗដែលបានប៉ះវា ។

# បទានុក្រម

១. **កាបំពុលទឹក** (Water Pollution) : ជាការបន្ថែមនូវសារធាតុទាំង ឡាយណាដែលធ្វើឱ្យមានផលប៉ះពាល់អវិជ្ជមានដល់ទឹក ឬសារពាង្គកាយដែលរស់នៅពឹងផ្អែកទៅលើនិងក្នុងទឹក ។

២. **វដ្តទឹក** (Water Cycle) ជាចលនានៃទឹកពីប្រភពទឹក ដូចជា

៣. បឹង ទន្លេ ស្ទឹង អូរ សមុទ្រ មហាសមុទ្រ លើដី ក្នុងដី និងពីរុក្ខជាតិទៅក្នុង បរិយាកាស បង្កើតបានជាកំណកអាកាស រួចក៏ធ្លាក់ត្រឡប់ទៅកាន់ប្រភពដើមវិញ ។

៤. **ជង្ហើមទឹក**(Aquifer) : ស្រទាប់សិលាឆ្អែតទឹកឬស្រទាប់ដែលមាន កម្ទេចកំណាធូរដែលមានប្រហោងពោរពេញទៅដោយទឹកឬជាស្រទាប់ សិលាដែលស្តុកទឹកនិងអាចឱ្យទឹកហូរក្នុងដីបាន ។

៥. **បរិយាកាស** (Atmosphere) : ជាល្បាយឧស្ម័នព័ទ្ធជុំវិញភព ។

៦. **សីតុណ្ហភាព** (Temperature) : ជារង្វាស់នៃចលនាថាម

ពលរបស់ ភាគល្អិតគិតជាមធ្យម ។

៧. **សម្ពាធបរិយាកាស (Air Pressure)** :បរិមាណនៃកម្លាំងខ្យល់ដែល បញ្ចេញមកលើតំបន់មួយនៃផ្ទៃលើ ។

៨. **បារ៉ូម៉ែត្រ (Barometer)** : ជាឧបករណ៍ដែលប្រើប្រាស់សម្រាប់វាស់ សម្ពាធខ្យល់ ។

៩. **តំបន់ជំនួបភ្ជាប់ឆ្លងត្រូពិច Iner-Tropical Convergence Zone-ITCZ)** ជាក្រវាត់សម្ពាធខ្សោយមួយដែលព័ទ្ធជុំវិញផែនដីនៅជិតអេក្វាទ័រ ។

១០. **មណ្ឌលខាប់(Astthenosphere)**:ជាស្រទាប់ទន់របស់ម៉ង់តូ ដែល មានបំណែក នៃមណ្ឌលថ្ម ធ្វើចលនាពីលើ ។

១១. **សំរាងប៉ូល (Aurora)** : ជាពន្លឺដែលបញ្ចេញដោយអាតូមនិងម៉ូលេគុលនៅក្នុងបរិយាកាសជាន់ខ្ពស់ ។

១២. **បណ្តុំរង្វិលខ្យល់ (Convection Cell)** : ជាលំនាំវិលវល់បណ្តាលមកពីការស្ទុះឡើងលើនិងការធ្លាក់ចុះនៃខ្យល់ ។

១៣. **ស្នូលផែនដី(Core)** : ជាស្រទាប់ក្នុងបង្អស់ លាតសន្ធឹងពី

ក្រោមម៉ង់តូទៅដល់ផ្ចិតផែនដី ។

១៤. **ឥទ្ធិពលកូរីយ៉ូលីស**(Coriolis Effect) : ជាចលនាវេរទិសរបស់វត្ថុពីទិសដៅត្រង់ដោយសាររង្វិលខ្វាល់របស់ផែនដី

១៥. **មាត់ភ្នំភ្លើង** (Crater) : ជារណ្ដៅរាងដូចឡាវស្ថិតនៅចំកណ្ដាល បំពង់ភ្លើង ។

១៦. **សំបកផែនដី** (Crust): ជាស្រទាប់ក្រៅគេបំផុតនៃផែនដី ។

១៧. **រញ្ជួយផែនដី** (Earthquake):ជារំញ័រកើតឡើងពីចលនារបស់សិលាក្រោមផ្ទៃផែនដី ។

១៨. **កម្លាំង** (Force): ជាការរុញ ឬទាញ ។

១៩. **ផូស៊ីល** (Fossil) : ជាស្លាកស្នាមនៃបុរេសារពាង្គកាយបានបន្សល់ ទុកនៅក្នុងសិលា ។

២០. **ទំនាញ**(Gravity): ជាកម្លាំងទាញទាំងអស់ទៅវិញទៅមក ។

២១. **ចំណុចក្តៅ** (Hot Spot) : ជាកន្លែងរូបធាតុចេញពីម៉ង់តូស្ទុះឡើង ហើយរលាយបង្កើតបានជាម៉ាក់ម៉ា ។

២២. **កម្លាំងនិចលភាព** (Intetia): ជាទំនោរនៃចលនារបស់អង្គវិលទាំងអស់ដើម្បីរក្សាចលនាវិលក្នុងទិសដៅត្រង់មួយ

២៣. **កំអែភ្នំភ្លើង** (Lava) : ជាម៉ាក់ម៉ាហូរឡើងមក លើផ្ទៃផែនដី ។

២៤. **មណ្ឌលថ្ម** (Lithosphere): ស្រទាប់រឹង[illegible]ក្រៅគេបំផុត ជា មណ្ឌលថ្ម ។

២៥. **មណ្ឌលម៉ាញេទិច** (Megnetosphére): ជាតំបន់មួយស្ថិតនៅក្នុង បរិយាកាសជាន់ខ្ពស់ផែនដីកន្លែងចលនារបសឧស្ម័នត្រូវបានគ្រប់គ្រង ដោយដែនម៉ាញេទិចរបស់ផែនដី ។

២៦. **ម៉ង់តូ** (Mantle): ជាស្រទាប់ស្ថិតនៅចន្លោះសំបក និងស្នូល ។

២៧. **ម៉ាស** (Mass):ជាបរិមាណនៃរូបធាតុនៅក្នុងវត្ថុមួយ ។

២៨. **អេលីបសូអ៊ីត**(Oblate Spheroid) :ជារូបរាងអង្គមួយ

ដែលមានលក្ខណៈប៉ោង នៅតំបន់អេក្វាទ័រ និងសំប៉ែត នៅប៉ូលទាំងពីរ ។

២៩. **ប៉ង់សៀ**(Pangaea) **:**ជាផ្ទាំងទ្វីបទាំងអស់ផ្តុំគ្នាជាផ្ទៃដីដ៏ធំមួយកាលពីអតីតកាល

៣០. **ទ្រឹស្តីផ្ទាំងតិចតូនិច** (Plate Tectonics) **:**ជាទ្រឹស្តីដែលពន្យល់ថាមណ្ឌលថ្ម របស់ផែនដីបានប្រេះបែកជាផ្ទាំងតិចតូនិចជាច្រើនបំណែក និងធ្វើចលនាពីលើមណ្ឌលខាប់ ។

៣១. **រលកP** (Primary Waves) **:**ជារលករញ្ជួយដីលឿនបំផុតដែលធ្វើចលនាឆ្លង កាត់រូបធាតុរឹង រាវ និងឧស្ម័ន ។

៣២. **រលកS** (Secondary Waves)**:** ជារលកនៃថាមពលដែលធ្វើចលនាឆ្លងកាត់ ផែនដី ។

៣៣. **រលករញ្ជួយដី** (Seismic Waves) **:** ជារលករញ្ជួយដីលឿនបន្ទាប់ពី រលក P ។

៣៤. **ក្រាបរលករញ្ជួយដី** (Seismogram)**:**ជាស្នាមនៃចលនារញ្ជួយដីដែល បង្កើតឡើងឧបករណ៍វាស់រញ្ជួយដី ។

៣៥. **រលកផ្ទៃលើ** (Surfaces Waves)៖ ជារលកដែលធ្វើឱ្យដីផ្លាស់ទីឡើងចុះជារង្វង់នៅពេលវាធ្វើចលនាតាមផ្ទៃលើ ។

៣៦. **ភ្នំភ្លើង** (Volcano)៖ ជាភ្នំដែលកើតឡើងនៅពេលសិលារលាយ ហៅម៉ាក់ម៉ាហូរចេញមកលើផ្ទៃផែនដី ។ ម៉ាក់មា ជាសិលារាវដែលផ្សំ ឡើងពីសិលារលាយឧស្ម័ន និងទឹកហើយមានប្រភពនៅក្នុងម៉ង់តូ ។

៣៧. **ទម្ងន់** (Weight)៖ជាកម្លាំងទំនាញនៅលើវត្ថុ មួយ ។

៣៨. **ខ្យល់បក់**(Wind)៖ជាចលនារបស់ខ្យល់តាមផ្ទៃដេកពីតំបន់ សម្ពាធខ្លាំងទៅតំបន់សម្ពាធខ្សោយ ។

៣៩. **វានរ**(Primate)៖ ក្រុមសត្វ រួមមានមនុស្ស ស្វា និងសត្វមានរូប រាងដូចស្វា ប៉ុន្តែគ្មានកន្ទុយ ។

៤០. **ផូស៊ីលកម្ម**(Fossiligation)៖ដំណើរបំលែងអង្គធាតុសររាង្គឱ្យទៅជាផូស៊ីល ។

៤១. **ស្រទាប់វិទ្យា**(Stratigraphy)៖សាខានៃធរណីវិទ្យាដែលសិក្សាពី លំដាប់លំដោយនៃកំណកំណើតសិលា ចំណែកថ្នាក់

នាមវលីទំនាក់ទំនងនៃស្រទាប់សិលានិងបំណែកស្រោយពន្យល់សិលាស្រទាប់ ។

៤២. **សន្ទស្សន៍**(Index) : ភស្តុតាងសញ្ញាសំគាល់ដែលបញ្ជាក់ថាអាចមានវត្តមានរបស់អ្វីមួយ ។

៤៣. **ស្ថានប្រព័ន្ធឬប្រព័ន្ធអេកូឡូស៊ី**(Ecosystem): សំណុំសារពាង្គកាយមាន ជីវិតទាំងអស់រួមជាមួយមជ្ឈដ្ឋានជីវិត និងអន្តរកម្មរវាង សារពាង្គកាយមានជីវិតទាំងនោះជាមួយមជ្ឈដ្ឋានជីវិត របស់វាដែលស្ថិតនៅក្នុងទីកន្លែងមួយកំណត់ ។

---

# ចប់ដោយបរិបូរណ៍

សូមអគុណ!!!

E_mail: heng_nlh@yahoo.com